ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមបុគ្គលិកសិក.

* ចំណងមិត្តភាពនិងការខ្ទបគ្គម្គគ្នាទៅវិញទៅមក
* ការពង្រឹងនិងពង្រីកចំណេះដឹង និង វិជ្ជាជីវៈ
* ការការពារផលប្រយោជន៍គ្នាទាំងផ្លូវចិត្ត - សម្ភារៈ

៤៩

# ទស្សនាវដ្ដី គ្រូបង្រៀន



ផ្ទះគ្រូបង្រៀន ខេត្តមណ្ឌលគិរី

## ត្រីមាសទី៣ ឆ្នាំ ២០១៦

ផ្សាយចេញរាល់ត្រីមាសពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ
១២៨B មហាវិថីព្រះនរោត្តម (ភ្នំពេញ)
ទូរស័ព្ទ : ០២៣ ២១៦ ១៨៤_០១២ ៦៣៨ ៨៨៩
អ៊ីម៉ែល : kta.amcek@gmail.com
Facebook: kta amcek

# មាតិកា

## គណៈកម្មការរៀបរៀង និង និពន្ធ

- លោក ជ័យ សយ្យនា
- លោក ថោង ប៊ូរ៉ាន់
- លោកស្រី គុយ ផល្លា
- លោក ជន ឈាងលី
- លោក ស្វាយ ឧិត្យ
- លោកស្រី អ៊ឹម ប៊ុណ្ណារី
- លោក ព្រុំ សាមិត
- លោកស្រី ម៉ក់ ណាង
- លោក ឆៀ សុផន
- លោកស្រី ថាច់ ធីសារ៉ែន
- លោក អ៊ុំម ជា
- សមាជិកសមាជិកា ស. ប. ស.ខ

## គណៈកម្មការត្រួតពិនិត្យ

- លោក យស់ អ៊ាង
- លោកស្រី ទន់ សាអ៊ីម
- លោកស្រី ប្រាក់ សូលីដា
- លោក រ័ត្ន ហួត
- លោក សួង សារុណា
- លោក ស៊ុង វ៉ាន់ថន
- លោក ស៊ិន ស៊ីម

## ការីកុំព្យូទ័រ

លោក ទេព្វឃិន សុវីរៈ

## ក្របខាងក្រៅ

- ពីមុខ : ផ្ទះគ្រូបង្រៀនខេត្តមណ្ឌលគិរី
- ពីក្រោយ : គ្រួសារអ្នកមុខអ្នកការនៅ ខេត្តស្ទឹងព្រៃ។


| ល.រ | ចំណងជើងអត្ថបទ | ទំព័រ |
|---|---|---|
| ១ | វិចារណកថា | ១ |
| | **វប្បធម៌ទូទៅ** | |
| ២ | ប្រទេសកម្ពុជាក្នុងសមាហរណកម្មសហគមន៍អាស៊ានឆ្នាំ២០១៥ (ត) | ២ |
| ៣ | ប្រកពនៃការអប់រំក្នុងពិភពលោក (ត) | ៥ |
| ៤ | វត្តអារាមជាមជ្ឈមណ្ឌលវប្បធម៌របស់ប្រជារាស្ត្រខ្មែរ | ៧ |
| | **ចិត្តវិទ្យាអប់រំ** | |
| ៥ | មាតាបិតាពុំមែនជាតុលាការ ពុំមែនជាថ្នាំគុកតែជាអ្នកនាំផ្លូវសម្រាប់បុត្រធីតា (ត) | ៩ |
| ៦ | ចលករសិក្សា (នៅមានត) | ១១ |
| ៧ | កុមារឈ្លាសវៃព្រោះបានធ្វើសកម្មភាពរៀន (ចប់) | ១៣ |
| | **ការអប់រំ និង គរុកោសល្យ** | |
| ៨ | សាកល្បងសិក្សាអំពីបញ្ហាស្រៈមួយចំនួនមិនរាប់ដាក់បញ្ចូលទៅក្នុងក្រុមស្រៈនិស្ស័យ | ១៥ |
| ៩ | ពិសោធប្រើប្រដាប់លេងនិងសម្ភារឧបទេសសម្រាប់អប់រំបុត្រធីតានិងសិស្ស | ១៨ |
| ១០ | អំពីនិបាតស័ព្ទ និងអយតនិបាត | ២០ |
| | **វិទ្យាសាស្ត្រព័ត៌មាន-បច្ចេកវិទ្យា** | |
| ១១ | ការដាក់បញ្ចូលឯកសារលើគេហទំព័រគ្រូ | ២២ |
| | **កំណាព្យ និង កម្សាន្ត** | |
| ១២ | ការអប់រំបញ្ចូលគ្នា (បទពាក្យប្រាំពីរ) | ២៤ |
| ១៣ | ថ្វីបើខ្លាំងគង់ចុះចាញ់ (បទពាក្យប្រាំពីរ) | ២៦ |
| | **វេទិកាស្វែងរក** | |
| ១៤ | ពុទ្ធសាសនានៅប្រទេសកម្ពុជា (ត) | ២៧ |
| ១៥ | ព្រលឹងជាតិ | ២៩ |
| | **ព័ត៌មាន** | |
| ១៦ | ប្រវត្តិបុណ្យចូលឆ្នាំខ្មែរ | ៣២ |
| ១៧ | មជ្ឈមណ្ឌលអន្តេវាសិកដ្ឋាននិស្សិតនារីឆ្នាំសិក្សា២០១៤-២០១៥ | ៣៤ |
| ១៨ | ចម្រៀងគោរពទង់ជាតិ (បទនគររាជ) | ៣៥ |
| ១៩ | ក្រុង ស្រុក ខណ្ឌ ឃុំសង្កាត់នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១២(តចប់) | ៣៧ |
| ២០ | ស្ថិតិសពខែឧសភា ឆ្នាំ២០១៥ ដល់ខែវិច្ឆិកា ឆ្នាំ២០១៥ | ៣៩ |



## ទូរស័ព្ទផ្ទះគ្រូបង្រៀន

| | | |
|---|---|---|
| ភ្នំពេញ | : | ០៨៩ ៦៨៤ ០៨១ |
| ព្រះសីហនុ | : | ០១២ ៦៥៩ ៥៦០ |
| សៀមរាប | : | ០១២ ៦៧៥ ៦៤០ |
| កំពង់ចាម | : | ០១១ ៧៤២ ២២៤ |
| ស្វាយរៀង | : | ០៩៧ ២៦៥៥ ៩៨៧ |
| ព្រៃវែង | : | ០១២ ៦៧១ ៦៤០ |
| កំពត | : | ០១២ ៨៥៦ ៧២២ |
| កែប | : | ០៩៧ ៨ ៧២១៨៨០ |
| តាកែវ | : | ០៩៧ ៩៧៦១ ៥៨៨ |
| រតនគិរី | : | ០៩៧ ៩០៤២ ៥៨៤ |
| ព្រះវិហារ | : | ០១២ ២១៨២៨១ |
| បាត់ដំបង | : | ០១២ ៦៧៣ ៦៦២ |
| ស្ទឹងត្រែង | : | ០១២ ៩៦៤ ៤៩៦ |
| មណ្ឌលគិរី | : | ០១១ ៨០៤ ៣៤៧ |

# វិចារណកថា

UNESCO បង្ហាញគំនិតថា ដើម្បីកសាងពិភពលោកឲ្យមានយុត្តិធម៌កាន់តែច្រើនក៏ដូចជាសន្តិភាព និងស្ថិរភាពដែរ មនុស្សនិងសង្គមត្រូវពង្រឹងអំណាចនៃសកម្មភាពចំណេះដឹង សមត្ថភាព និងតម្លៃរបស់ខ្លួន យកចិត្តទុកដាក់ដល់ភាពចាំបាច់នៃការប្រែប្រួលឈានឡើងដោយមនសិការខ្ពស់។ ទាំងអស់គ្នាយល់ស្របនិងទទួលស្គាល់ជាសាកលថា "ការអប់រំដើម្បីអភិវឌ្ឍឍបិតបេរ" គឺជាផ្នែកបំពេញបង្គ្រប់ ដល់ការអប់រំប្រកបដោយគុណភាព និងក៏ជាចលករចាំបាច់ដែរនៃការអភិវឌ្ឍឍបិតបេរ។ កិច្ចព្រមព្រៀង MASCATE នៃប្រទេស OMAN ដែលជាផ្លែផ្កានៃការប្រជុំពិភពលោកអំពីការអប់រំសម្រាប់ទាំងអស់គ្នាក្នុងឆ្នាំ២០១៤ និងក្រុមការងារបើកទូលាយនៃមហាសន្និបាត អ.ស.ប. ទាក់ទងនឹងគោលដៅនៃការអភិវឌ្ឍឍបិតបេរ ទាំងនេះគឺជាឧបករណ៍ដែលលើកឡើងថា ការអភិវឌ្ឍឍបិតបេរជាទិសដៅសំខាន់នៃកម្មវិធីការងារក្រោយឆ្នាំ២០១៥។

សូមរំលឹកថា នាឆ្នាំ២០១៣ សន្និសីទលើកទី៣៧នៃ UNESCO បានកំណត់កម្មវិធីសកម្មភាពរួមសម្រាប់ "ការអប់រំដើម្បីអភិវឌ្ឍឍបិតបេរ" និងចាត់ទុកថាកម្មវិធីនេះក៏ជាតំណនៃកម្មវិធី១០ឆ្នាំ (២០០៥-២០១៤) របស់ អ.ស.ប. ដែរ។

ផ្អែកលើលទ្ធផលនៃកម្មវិធី១០ឆ្នាំ កម្មវិធីសកម្មភាពរួមមានគោលបំណងជំរុញនិងពង្រឹងសកម្មភាពជាក់ស្តែងក្នុងវិស័យ "ការអប់រំដើម្បីអភិវឌ្ឍឍបិតបេរ" ដែលចាត់ទុកជាការណែនាំរបស់ប្រទេសសមាជិកទាំងអស់ ចំពោះថ្នាក់ដឹកនាំថ្នាក់ប្រតិបត្តិ និងតួអង្គពាក់ព័ន្ធទាំងអស់ សម្រាប់ធ្វើឲ្យសម្រេចកម្មវិធីសកម្មភាពរួមនេះ និងពន្យល់លម្អិតពីតួនាទីរបស់ UNESCO ផងដែរ។

នេះជាឯកសារបើកផ្លូវ ឆ្ពោះទៅសម្រេចគោលដៅរំពឹងទុកនៃ "ការអប់រំដើម្បីអភិវឌ្ឍឍបិតបេរ" ដោយជោគជ័យ។

**គណៈកម្មាធិការស.ប.ស.ខ.**




# ប្រទេសកម្ពុជាក្នុងសមាហរណកម្មសហគមន៍អាស៊ានឆ្នាំ២០១៥ (ត)

(ប្រភព : ចក្ខុវិស័យអាស៊ាន២០២០ បណ្ឌិត ស៊ន សំណាង)

បន្ទាប់ពីដំណើរការរៀបចំចក្ខុវិស័យអាស៊ាន ក្តីស្រមៃនៃការបង្កើតសហគមន៍នៃបណ្តាសង្គមអាស៊ានគឺៈ

- ស្រមៃចង់ឲ្យអាស៊ីអាគ្នេយ៍ទាំងមូលមុនឆ្នាំ២០២០យ៉ាងយូរ ប្រែក្លាយពីសមាគមទៅជាសហគមន៍អាស៊ានមួយប្រកបដោយមនសិការចំពោះចំណងទាក់ទងផ្នែកប្រវត្តិសាស្ត្រ និងមានការយល់ដឹងអំពីបេតិកភ័ណ្ឌវប្បធម៌ និងផ្សារភ្ជាប់ដោយអត្តសញ្ញាណរួមមួយនៃតំបន់។

- ក្តីស្រមៃបណ្តាសង្គមនៅអាស៊ានមានលក្ខណៈរស់រវើក និងបើកចំហស្របតាមអត្តសញ្ញាណជាតិរៀងៗខ្លួន ដែលប្រជាជនគ្រប់រូបទទួលបានឱកាសដោយសមធម៌សម្រាប់ការអភិវឌ្ឍដោយមិនគិតអំពីភេទ ពូជសាសន៍ សាសនា ភាសា សារតារខាងសង្គម និងវប្បធម៌ឡើយ។

- ស្រមៃចង់ឃើញតំបន់មួយប្រកបដោយភាពស្និទ្ធស្នាល និងមានការថែទាំគាំពារដែលក្នុងនោះគ្រួសាររឹងមាំ ដែលជាអង្គការគ្រឹះសង្គម ដោយយកចិត្តទុកដាក់ចំពោះកុមារ យុវជន ស្ត្រី និងមនុស្សចាស់ដោយមានភាពយុត្តិធម៌សង្គម និងការគ្រប់គ្រងដោយច្បាប់។

- ស្រមៃចង់ឃើញតំបន់អាស៊ានមួយប្រកបដោយការប្រកួតប្រជែងផ្នែកបច្ចេកវិទ្យា (A technologically competitive ASEAN) ដែលមានសមត្ថភាពបច្ចេកវិទ្យាជាយុទ្ធសាស្ត្រដោយមានធនធានមនុស្ស មានការបណ្តុះបណ្តាល មានបច្ចេកវិទ្យាមួយសមស្រប មានបណ្តាញរឹងមាំនៃស្ថាប័នបច្ចេកវិទ្យាសាស្ត្រ និងមជ្ឈមណ្ឌលសុក្រឹតភាពដើម្បីប្រែក្លាយប្រព័ន្ធបច្ចេកវិទ្យាទៅជាមូលដ្ឋានសេដ្ឋកិច្ចដ៏រឹងមាំ។

- ស្រមៃចង់បានអាស៊ានមួយពោរពេញទៅដោយយន្តការច្បាស់លាស់សម្រាប់អភិវឌ្ឍដោយចីរភាព ដើម្បីធានាបាននូវការថែទាំបរិស្ថានក្នុងតំបន់ ចីរភាពនៃធនធានធម្មជាតិ និងគុណភាពជីវភាពរស់នៅរបស់ប្រជាជន។

- ស្រមៃចង់ឃើញនៅក្នុងតំបន់អាស៊ានវិវត្តនៃបណ្តាវិធានការបណ្តុះឥរិយាបថ និងកិច្ចសហប្រតិបត្តិការ ដើម្បីដោះស្រាយបញ្ហាដែលអាចកើតមានក្នុងកម្រិតតំបន់ ក្នុងនោះការបំផុល ការធ្លាក់ចុះបរិស្ថាន ជំនួញគ្រឿងញៀន ការជួញដូរស្ត្រី និងកុមារ ឧក្រិដ្ឋកម្មឆ្លងដែន និងបញ្ហាសាសនា។
- ស្រមៃចង់ឃើញបណ្តាប្រជាជាតិមួយគ្រប់គ្រងដោយមានការយល់ព្រម និងមានការចូលរួមកាន់តែច្រើនពីប្រជាជនដោយផ្តោតលើសុខុមាលភាព សេចក្តីថ្លៃថ្នូរ និងអំពើល្អក្នុងសហគមន៍។



## III. បញ្ហាប្រឈមផ្សេងៗរបស់បណ្តាប្រទេសក្នុងតំបន់អាស៊ាន

ប្រជាជនជាង៦០០លាននាក់ដែលកំពុងរស់នៅក្នុងតំបន់សមាគមអាស៊ាននេះមានសភាពលក្ខណៈមិនដូចគ្នាឡើយ គឺការប្រើភាសា វប្បធម៌ ទំនៀមទម្លាប់ និងប្រពៃណី សាសនា និងសេដ្ឋកិច្ចក៏ខុសគ្នាស្រឡះ។ បណ្តាប្រទេសជាអតីតពិភពលោកឥណ្ឌូចិនដែលគ្របដណ្តប់ទៅលើប្រទេសវៀតណាម កម្ពុជា និងឡាវ ហើយថែមទៅលើប្រទេសភូមា និងប្រទេសថៃថែមទៀត។ ប្រជាជនភាគច្រើននៅភូមា កម្ពុជា ថៃ ឡាវ និងវៀតណាមកាន់ព្រះពុទ្ធសាសនា និងប្រកបមុខរបរកសិកម្ម។ ចំណែកឯ បណ្តាប្រទេសនៅពិភពម៉ាឡេវិញ គឺជាដែនដីដែលពោរពេញដោយកោះ ឬជាទីប្រជុំកោះរួមមានប្រទេសម៉ាឡេស៊ី ឥណ្ឌូណេស៊ី ហ្វីលីពីន សិង្ហបុរី ព្រុយណេ ដែលប្រជាជនភាគច្រើនគោរពនូវអ៊ីស្លាមសាសនាដូចជានៅឥណ្ឌូណេស៊ី និងនៅម៉ាឡេស៊ី និងព្រុយណេ ហើយប្រជាជនមួយភាគធំ ទៀតនៅហ្វីលីពីនគឺជាអ្នកកាន់សាសនាគ្រិស្ត និងជាប្រទេសឧស្សាហកម្ម។ សាសនាទាំងអស់នេះកំពុងមានបញ្ហាដូចជានៅប៉ែកខាងត្បូងនៃប្រទេសហ្វីលីពីននៅកោះមីនដាណាវ (Mindanao)

ស៊ុយលុយ(Sulu) និងហ្សូឡូ (Jolo) គឺជាទំនាស់ពួកអ៊ីស្លាម និងគ្រិស្តសាសនា ដែលបច្ចុប្បន្ននេះកងទ័ពព្រៃ Abu Sayyaf ប្រមាណ១២០០០នាក់របស់រណសិរ្សម៉ូរ៉ូរំដោះអ៊ីស្លាម ដែលបន្តប្រឆាំងនឹងរដ្ឋាភិបាលហ្វីលីពីនគោរពគ្រិស្តសាសនាកាលពីឆ្នាំ២០១១។ ចំណែកប្រជាជនមួយចំនួនទៀតនៅភាគខាងត្បូងនៃប្រទេសថៃដូចជានៅខេត្តណារ៉ាធីវ៉ាត (Narathiwat) ប៉ាត្តានី (Pattani) និងយ៉ាឡា(Yala) ពួកអ៊ីស្លាមជ្រុលនិយមជាច្រើនរយនាក់ប្រដាប់ដោយកាំភ្លើង និងខ្លះទៀតប្រដាប់ដោយខ្វែរ កាំបិត និងពូថៅបានវាយប្រហារជាបន្តបន្ទាប់ទៅលើបន្ទាយទាហាន និងស្នងការដ្ឋានប៉ូលិស។ ចាប់ពីឆ្នាំ២០១៥មកពួកថៃអ៊ីស្លាមជ្រុលនិយមបានប្តូរយុទ្ធសាស្ត្រ មិនសូវសម្លាប់តំណាងអាជ្ញាធរ ប៉ូលិសឬទាហានដូចមុនទៀតទេ តែវាយប្រហារទៅលើលោកសង្ឃ គ្រូបង្រៀន ឬពុទ្ធបរិស័ទវិញម្តង។ សកម្មភាពទាំងនេះបានជំរុញឲ្យរដ្ឋាភិបាលថៃបារម្ភថាអំពើហិង្សាអាចនឹងរាលដាលចេញពីខេត្តអ៊ីស្លាមទាំងបីចូលទៅដល់តំបន់ផ្សេងៗ និងរាលដាលទៅដល់ទីក្រុងបាងកកតែម្តង។ ប្រទេសមីយ៉ាន់ម៉ាក៏មានទំនាស់សាសនារវាងព្រះពុទ្ធសាសនាជាមួយជនជាតិភាគតិចជាច្រើន ដែលកាន់សាសនាគ្រឹស្ត និងអ៊ីស្លាមសាសនា។ មីយ៉ាន់ម៉ាមានន័យថាពូជសាសន៍ដែលកើតមុនគេនៅក្នុងលោកិយ។ កងទ័ពរដ្ឋាភិបាលតែងតែបានដុតបំផ្លាញគ្មានសល់ភូមិ ស្រុក និងស្រូវអង្ករបស់ពួកKarens បានកាប់សម្លាប់បុរស និងរំលោភស្ត្រី។ ពួក Karens ជាជនជាតិភាគតិចដែលគោរពអ៊ីស្លាមសាសនា ហើយមានចំនួនច្រើនជាងជនជាតិភាគដទៃរហូតដល់៧លាននាក់ដែលតែងតែប៉ះទង្គិចជាមួយព្រះពុទ្ធសាសនាជាញឹកញាប់ដោយរងរបួស និងស្លាប់ទាំងសងខាង ហើយនៅឆ្នាំ២០១៤កន្លងទៅនេះត្រូវក្រុមភេរវករអាល់កៃដាបានកំណត់យកប្រទេសនេះជាគោលដៅក្នុងការវាយប្រហារផង។ ចំណែកឯនៅប្រទេសវៀតណាមវិញពួកម៉ុងតាញ៉ាមួយភាគធំជាអ្នកកាន់សាសនាប្រូតេស្តង់(Protestant) ហើយរដ្ឋាភិបាលវៀតណាមធ្វើទុក្ខបុក-ម្នេញ ជាហេតុបង្កឲ្យមានភាពតានតឹងជាមួយប្រជាជនវៀតណាម ដែលជាអ្នកប្រកាន់ព្រះពុទ្ធសាសនា។ ចំពោះប្រទេសកម្ពុជាវិញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់យកព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ក៏ប៉ុន្តែក៏មានសាសនាដទៃទៀតដែលកំពុងមានសុខដុមនីយកម្មជាមួយគ្នាសម្រាប់សេរីភាពក្នុងជំនឿ។ តាមតួលេខឆ្នាំ២០១១ ព្រះពុទ្ធសាសនាមានវត្តចំនួន៤៣៩២វត្ត វត្តមហានិកាយ២២៤១វត្ត និងព្រះសង្ឃចំនួន៥៤៧៦៤អង្គ មហានិកាយ៥៣៤៥៩អង្គ។ សាសនាគ្រិស្ត គឺព្រះវិហារកាតូលិក២៩ សាលា១៥ ស្នាក់ការ៣៩ ព្រះវិហារប្រូតេស្តង់៣៤១ សាលា២៤៨ ស្នាក់ការ៨៨៣។ សាសនាឥស្លាមមានព្រះវិហារ២៤០ សាលា២០១ និងស៊ូរ៉ាវ៣៧៤។ សាសនាទាំងអស់នេះកំពុងរួមគ្នាជួយបណ្តុះបណ្តាលធនធានមនុស្សទាំងចំណេះដឹង សីលធម៌ និងជំនាញបច្ចេកទេស និងរួមគ្នាកសាងសន្តិភាពស្របតាមគោលនយោបាយរបស់រដ្ឋា-ភិបាលលើវិស័យសាសនា។ ទន្ទឹមនឹងនេះសាសនិកនៃសាសនាគួរស្វែងយល់ពីតម្លៃនៃទស្សនវិជ្ជារបស់សាសនានីមួយៗ ដើម្បីរក្សាតម្លៃសន្តិភាពឲ្យបានយូរអង្វែង ដែលជាក្តីសង្ឃឹមរបស់អ្នកវិនិ-

# ប្រភពនៃការអប់រំក្នុងពិភពលោក (ត)

## ៥.៦. ការអប់រំនៅក្រុងរ៉ូមបុរាណ

នៅពេលដែលវប្បធម៌និងការអប់រំរបស់ក្រិកកំពុងតែបានអភិវឌ្ឍនៅសមុទ្រមេឌីទែរ៉ានេប៉ែកខាងលិចនោះ ពួករ៉ូម៉ាំងកំពុងតែពង្រឹងជំហរខាងនយោបាយនៅលើឧបទ្វីបអ៊ីតាលី (Italian Peninsula) និងពាសពេញសមុទ្រមេឌីទែរ៉ានេប៉ែកខាងលិច។ នៅក្នុងចលនារបស់គេពីសាធារណរដ្ឋដ៏តូច ទៅជាចក្រភពដ៏ធំនោះ ពួករ៉ូម៉ាំងបានផ្ដើមកាន់កាប់ ឬត្រួតត្រាជាមុនដោយសង្គ្រាមនិងនយោបាយ។ នៅពេលមួយនោះ ពួកគេបានក្លាយទៅជាអំណាចចក្រភព ពួកគេបានផ្ចង់អារម្មណ៍ទៅលើរដ្ឋបាលច្បាប់និងការទូត ដែលចាំបាច់ដល់ការថែរក្សាចក្រភព។ ដោយមូលហេតុដែលគេបានកត់សម្គាល់ឃើញថា ពួកក្រិកយកចិត្តទុកដាក់តែទៅលើទស្សនវិជ្ជានោះពួករ៉ូម៉ាំងបែរជាផ្ដោតអារម្មណ៍ទៅលើការអប់រំអ្នកនយោបាយជាក់ស្ដែង អ្នករដ្ឋបាលដែលមានសមត្ថភាព និងជំនាញទូទៅ។

### ក.ការចូលរៀន

នៅក្នុងប្រទេសក្រិកបុរាណ មានតែពួករ៉ូម៉ាំងមួយភាគតូចប៉ុណ្ណោះដែលបានទទួលការអប់រំក្នុងប្រព័ន្ធ។ ការអប់រំទុកសម្រាប់តែមនុស្សដែលមានលុយបង់ថ្លៃសាលារៀន និងពេលវេលាសិក្សា។

### ខ.សាលាបឋមសិក្សា និងមធ្យមសិក្សា

ដោយហេតុថាក្មេងស្រីវណ្ណៈខ្ពស់ ជារឿយៗបានរៀនអាន និងសរសេរនៅផ្ទះ ឬត្រូវបានបង្រៀនដោយគ្រូបង្រៀនសិស្សទោលនោះ ក្មេងប្រុសដែលមកពីគ្រួសារទាំងនេះ បានចូលរៀននៅសាលាបឋមសិក្សា(ludus) ហើយបន្ទាប់មកមធ្យមសិក្សាដែលត្រូវបានបង្រៀនដោយគ្រូដែលបង្រៀនវេយ្យាករណ៍ក្រិក និងឡាតាំង។ ក្មេងប្រុសត្រូវបានគេជូនទៅរៀននៅសាលារៀនទាំងនេះដោយពួកទាសករក្រិកដែលមានការអប់រំ ត្រូវបានគេហៅថាPedagogues(=Teachers) ដែលពាក្យគរុកោសល្យ(Pedagogy) មានន័យថាសិល្បៈនៃការបង្រៀនបានក្លាយចេញពីពាក្យនេះឯង។

### គ.ឧត្ដមគតិនៃវាគ្មិន

ឧត្ដមគតិអប់រំរបស់ពួករ៉ូមត្រូវបានបញ្ជាក់ដោយវាគ្មិន។ វាគ្មិនរ៉ូម៉ាំងដែលប្រកបដោយឧត្ដមគតិ គឺជាមនុស្សដែលមានការអប់រំពីជីវិតសាធារណៈយ៉ាងទូលំទូលាយ និងដោយសេរី ដូចជា សមាជិកព្រឹទ្ធសភា មេធាវី គ្រូបង្រៀន មន្ត្រីរាជការនិងអ្នកនយោបាយ។ ដើម្បីពិនិត្យមើលឧត្ដមគតិនៃសិល្បៈខាងការថ្លែងសុន្ទរកថារបស់រ៉ូម៉ាំង យើងត្រឡប់ទៅមើលQuintilian។

**Quintilian : ជំនាញច្បាស់លាស់នៃការថ្លែងសុន្ទរកថា :** Marcus Fabias Quintilnius (A.D. 35-95) ឬហៅថា Quintilian គឺជាវោហារសាស្ត្រវិទូ ដែលត្រូវបានគេទទួលស្គាល់ដោយកម្រិតខ្ពស់បំផុតរបស់ចក្រភពរ៉ូម៉ាំង។ អធិរាជបានតែងតាំងគាត់ទៅដល់កម្រិតប្រធាននៃវោហារសាស្ត្រឡាតាំងទីមួយ។

## ឃ.ការបង្រៀនដោយផ្អែកលើដំណាក់កាលនៃការលូតលាស់

Quintilian`s *Institutio Oratoria* ដែលជាអភិប្រាយអប់រំជាប្រព័ន្ធបានរាប់បញ្ចូលៈ

1. ការអប់រំដែលជាការរៀបចំដើម្បីសិក្សាវោហារសាស្ត្រ។
2. ទ្រឹស្តីអប់រំនិងវោហារសាស្ត្រ។
3. ការប្រតិបត្តិនៃការនិយាយជាសាធារណៈ ឬការថ្លែងទៅកាន់ទស្សនិកជន។

Quintilian បានបង្កើតចំណុចអប់រំដ៏សំខាន់ ដែលការបង្រៀនគួរតែផ្អែកទៅលើដំណាក់កាលនៃការលូតលាស់ និងការអភិវឌ្ឍមនុស្ស។ ដោយការប្រមើលមើលការយកចិត្តទុកដាក់របស់គ្រូសម័យទំនើប នៃភាពខុសគ្នារបស់សិស្សម្នាក់នោះគាត់បានផ្តល់ដំបូន្មានថា ការបង្រៀនគួរតែមានភាពសមរម្យដល់ការត្រៀមជាស្រេច និងបំណិនរបស់សិស្ស។ គាត់បានបញ្ជាក់នូវសារៈសំខាន់នៃវ័យដើមកុមារភាពក្នុងការបង្កើតអាកប្បកិរិយា ហើយគាត់បានផ្តល់យោបល់ថា គ្រូបង្រៀនត្រូវ ជំរុញទឹកចិត្តសិស្ស ដោយធ្វើឲ្យការសិក្សាមានការចាប់អារម្មណ៍ និងការទាក់ទាញ។

សម្រាប់ដំណាក់កាលដំបូងពីពេលកើតរហូតដល់អាយុ៧ឆ្នាំ នៅពេលដែលកុមារកំពុងមានសន្ទុះចិត្ត និងយកចិត្តទុកដាក់ជាមួយនឹងតម្រូវការ និងចំណង់ភ្លាមៗនោះ គាត់បានផ្តល់ដំបូន្មានដល់ឪពុកម្តាយឲ្យចេះជ្រើសរើសមេដោះ គ្រូបង្រៀនដែលមានការបណ្តុះបណ្តាលល្អ និងនិយាយបានត្រឹមត្រូវ និងមិត្តភ័ក្តិសម្រាប់កុមារផង។

### ង.ការអាន និងការសរសេរ

ក្នុងដំណាក់កាលទី២នៃការអប់រំរបស់Quintilianពីអាយុ៧-១៤ឆ្នាំ កុមារគួររៀនពីបទពិសោធដែលទាក់ទងដល់ឥន្ទ្រីយារម្មណ៍ បង្កើតគំនិតច្បាស់លាស់ និងបណ្តុះបណ្តាលលំនឹករបស់គេ។ ឥឡូវនេះគេរៀនសរសេរភាសាដែលគេចេះនិយាយរួចហើយ។ គ្រូបង្រៀនដំបូង (Litterator) ដែលបានបង្រៀនអាន និងសរសេរនៅបឋមសិក្សានោះ ត្រូវតែមានអត្តចរិតថ្លៃថ្នូរ និងមានសមត្ថភាពបង្រៀន។ ការបង្រៀនខាងអំណាន និងសំណេរគួរតែយឺតៗ និងហ្មត់ចត់ ហើយកុមារគួររៀនអក្ខរក្រម ដោយប្រើប្រាស់លំដាប់អក្សរធ្វើពីភ្លុក។ ដូចជា Montessori ច្រើនសតវត្សក្រោយមកQuintilianបានផ្តល់ដំបូន្មានថាកុមាររៀនសរសេរអក្សរដោយតាមដានរូបរាងតួអក្សរ។ ដោយប្រមើលមើលការអប់រំសម័យទំនើប គាត់បានអះអាងថា សាលារៀនសព្វថ្ងៃនេះ រាប់បញ្ចូលទាំងការចេញលេង ដើម្បីលេងល្បែង និងការកំសាន្តផ្សេងៗ ដើម្បីឲ្យសិស្សមានកម្លាំង និងថាមពលថ្មីឡើងវិញ។

### ច.ការសិក្សាសិល្បៈសេរី

សម្រាប់ដំណាក់កាលទី៣នៃការអប់រំនេះពីអាយុ១៤-១៧ឆ្នាំ បានសង្កត់ធ្ងន់ទៅលើសិល្បៈសេរី។ សិស្សបានសិក្សាវេយ្យាករណ៍ក្រិក និងឡាតាំង អក្សរសិល្ប៍ ប្រវត្តិវិទ្យា ទេវកថាវិទ្យាដោយប្រើភាសា និងវប្បធម៌ទាំង២។ សិស្សក៏បានសិក្សាផងដែរនូវតន្ត្រី ធរណីមាត្រសាស្ត្រ តារាសាស្ត្រ និងកីឡាកាយសម្ព័ន្ធ។ (*នៅមានត*)

*អនុបណ្ឌិត* **សូ សុធីរ**

# វត្តអារាមជាមជ្ឈមណ្ឌលវប្បធម៌របស់ប្រជារាស្ត្រខ្មែរ

## ពុទ្ធសាសនានៅកម្ពុជា

ប្រជារាស្ត្រខ្មែរជាង៩៥% ជាអ្នកកាន់ពុទ្ធសាសនា។ ជីវិតរបស់គេបានផ្សារភ្ជាប់ទៅនឹងវត្តអារាមតាំងពីកើតរហូតដល់ស្លាប់។ ដោយសារប្រជារាស្ត្រខ្មែរទាំងអស់គ្នាផ្ដោតចិត្តគំនិត និងសកម្មភាពទៅលើតែចំណុចរួមមួយគឺវត្តអារាម ទើបវត្តអារាមបានក្លាយទៅជាមជ្ឈមណ្ឌលវប្បធម៌របស់គេ។

**១-តើពុទ្ធសាសនាចូលមកដល់ប្រទេសកម្ពុជាតាំងពីពេលណាមក**?

តាមរយៈឯកសារឥណ្ឌា ចិន និងការស្រាវជ្រាវខាងបុរាណវិទ្យាបញ្ជាក់ថា មនុស្សខ្មែរបានរស់នៅលើទឹកដីសុវណ្ណភូមិនេះតាំងតែពីរាប់ពាន់ឆ្នាំមកហើយ។ គឺជាប្រជាជាតិខ្មែរដែលមានវ័យចំណាស់ជាងគេមួយ ក្នុងចំណោមប្រជាជាតិនៅអាស៊ីអាគ្នេយ៍នេះ។ ប្រជាជាតិខ្មែរបានស្ថាបនាប្រព័ន្ធគ្រប់គ្រងប្រទេសរបស់ខ្លួន មានការរីកចម្រើនគ្រប់វិស័យ តាំងពីមុនពេលដែលពុទ្ធសាសនា និងសាសនាព្រាហ្មណ៍ចូលមកដល់។ ខ្មែរមានភាសាដោយឡែករបស់ខ្លួន មានជំនឿសម្រាប់គោរពបូជារបស់ខ្លួន។ រីឯវប្បធម៌ដែលចូលមកពីក្រៅមានវប្បធម៌ឥណ្ឌានិងចិន គឺគ្រាន់តែជាការផ្ដល់កម្លាំង ឬជាពន្លឺជួយជំរុញឲ្យវប្បធម៌ខ្មែររីកចម្រើន និងអភិវឌ្ឍបានយ៉ាងឆាប់រហ័សតែប៉ុណ្ណោះ ដោយហេតុភាពរលាយនៃវប្បធម៌បរទេសមកជាវប្បធម៌ខ្មែរនេះហើយ ទើបប្រទេសដែលជាម្ចាស់ដើមនៃវប្បធម៌នោះ ពុំអាចរកភស្តុតាងនៃវប្បធម៌របស់ខ្លួនឃើញនៅប្រទេសខ្មែរយើង។ ដូនតាខ្មែរជាអ្នកមានទេពកោសល្យខាងថ្នៃប្រឌិត មានកម្លាំងខាងបញ្ញាដ៏អស្ចារ្យណាស់ខាងការបង្កើតថ្មី។ ការណ៍ដែលលោកមិនចេះចម្លងតាមគ្នានេះហើយ បានជាវិស័យសិល្បៈវប្បធម៌ខ្មែរមានខ្លឹមសារ និងរូបភាពយ៉ាងសម្បូរបែប។ សិល្បៈវប្បធម៌ដ៏សម្បូរនោះ មានមជ្ឈមណ្ឌលដោយឡែកពីគ្នាប៉ុន្តែទាំងអស់គ្នាដើរតាមក្បួនខ្នាតជាមូលដ្ឋានរួមមួយ ដែលជាអត្តសញ្ញាណរបស់ជាតិ។

ក្នុងពេលដែលសាសនាព្រាហ្មណ៍ជាសាសនារបស់ប្រទេសនោះ ព្រះមហាក្សត្រនិងរាជបណ្ឌិតបានកសាងប្រាសាទជាច្រើន (រាប់ពាន់ប្រាសាទ)។ ប្រាសាទទាំងអស់នោះ ទោះបីស្ថិតក្នុងរចនាបថជាមួយគ្នា ក៏មានលក្ខណៈពិសេសពុំដូចគ្នាទេ ទំហំកម្ពស់ ទីតាំង តុបតែងលម្អក្បូរក្បាច់ខុសគ្នា។ ប៉ុន្តែអ្វីដែលដូចគ្នានោះ គឺប្រាសាទទាំងអស់នោះជាទីគោរពសក្ការបូជា និងជាកន្លែងរក្សាទុកឯកសារដូចគ្នា។

លុះដល់ពេលដែលពុទ្ធសាសនាមហាយានមកជំនួសសាសនាព្រាហ្មណ៍វិញ ប្រាសាទទាំងឡាយនោះមិនគ្រាន់តែជាទីសក្ការបូជា ជាបណ្ណាល័យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាសាលារៀន ជាមហាវិទ្យាល័យរបស់ជាតិទៀតផង។

ឧទាហរណ៍ : ប្រាសាទព្រះខ័ន ប្រាសាទតាព្រហ្មជាដើម។ សិលាចារឹក(តាព្រហ្ម សៀមរាប

អង្គរ) ឬ "បុរីរាជវិហារ" បញ្ជាក់ថា បុរីរាជវិហារនេះមានការជួយឧបត្ថម្ភដោយស្រុកចំនួន៣១៤០ សម្រាប់ឧបត្ថម្ភចំពោះបុរស៤០០នាក់ មានអធិការ(មហាថេរ)១៨អង្គ មានអធិការរង(អនុត្ថេរ) ២៧៤០អង្គ អ្នកបម្រើ២២៣២នាក់ រួមទាំងបរិចារិក(ស្រីរបាំ) ៦១៥នាក់ រួមទាំងអ្នកសំណាក់នៅក្នុងនោះផងមានចំនួន១២៦៤០នាក់។ រីឯអ្នកបម្រើមាន ៦៦៦២៥សរុបទាំងអស់មាន៧៩២៦៥នាក់ រួមទាំងជាតិភូមាផង។

នៅទីនោះមាន ៖

- លំនៅថ្ម ៥៦៦កន្លែង
- លំនៅឥដ្ឋ២៨៨កន្លែង
- ស្រះទទឹង ៧៦ព្យាម គុណនឹងបណ្ដោយ១១៥០ព្យាម។
- ភិក្ខុសង្ឃ៤៣៩អង្គទទួលភត្តរាល់ថ្ងៃក្នុងព្រះរាជមន្ទីរ សិស្សមាន៩៧០នាក់ សរុបទាំងអស់មាន១៤០៩នាក់។

នៅក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ ដែលជាព្រះរាជាគោរពពុទ្ធសាសនាព្រះអង្គបានកសាងអរោគ្យសាលា (មន្ទីរពេទ្យ) ចំនួន១០២កន្លែង មានទេវរូប៧៩៨អង្គ តម្កល់នៅទូទាំងប្រទេស។ ដើម្បីព្យាបាលអ្នកជំងឺនៅគ្រប់មន្ទីរពេទ្យទាំងនោះ គេត្រូវចំណាយអង្ករចំនួន ១១៧ ២០០ខារីកា។ អង្ករនោះបានមកពីស្រុកចំនួន ៨៣៨។ បុគ្គលិកអ្នកបម្រើនៅមន្ទីរពេទ្យមាន ៨១ ៦៤០នាក់។

ដល់មកក្រោយសម័យអង្គរ ពុទ្ធសាសនាហីនយាន បានចូលមកជំនួសពុទ្ធសាសនាមហាយាន ពេលនោះវត្តអារាមក៏មានតួនាទីដូចប្រាសាទសិលាពីបុរាណដូច្នេះដែរ។

តាមពិតទៅពុទ្ធសាសនានិងសាសនាព្រាហ្មណ៍មកដល់ប្រទេសខ្មែរក្នុងពេលប្រហាក់ប្រហែលគ្នា។ គម្ពីរពុទ្ធសាសនាបានផ្ដល់ព័ត៌មានថា ក្រោយពេលធ្វើតតិយសង្គាយនារួចក្នុងវង្វង់ពុទ្ធសតវត្សទី៣ ព្រះមហាថេរមួយអង្គព្រះនាមមហាមោគ្គល្លីបុត្តតិស្សៈ បានចាត់ចែងបញ្ជូនព្រះថេរ២អង្គគឺ **ព្រះសោណត្ថេរ និងព្រះឧត្តរត្ថេរ** ឲ្យចេញពីជម្ពូទ្វីប "ឥណ្ឌា" មកផ្សាយពុទ្ធសាសនានៅសុវណ្ណភូមិយើងនេះ។

តាមប្រភពឯកសារចិនថា ប្រទេសខ្មែរនិងចិនមានទំនាក់ទំនងជាមួយគ្នាតាំងពីមុនគ្រិស្តសករាជជាច្រើនរយឆ្នាំ។ ប៉ុន្តែឯកសារដែលជាភស្តុតាងរាប់ទុកជាផ្លូវការនោះ គឺរាប់ពីគ្រិស្តសតវត្សទី៣ រហូតមក។ តាមរយៈឯកសាររបស់ចិនដដែលនោះយើងអាចដឹងបានថា ចិនមកដល់ប្រទេសខ្មែរយើង (ដែលកាលណោះមានឈ្មោះថា Founan) តាំងពីមុនឆ្នាំ២៣១ នៃគ.ស.បន្តិច និងមានទំនាក់ទំនងជាមួយគ្នាពីឆ្នាំ២៤៣ នៃគ.ស. ដល់៤៣៤ នៃគ.ស.។ នៅក្នុងរជ្ជកាលព្រះចៅក្រុងចិន នាម វូ ចិនបានបញ្ជូនទូត២រូប មកកម្ពុជា គឺ **កាំង ថៃ** និង**ជូ យីង**។ ទូតទាំងពីររូបនេះបានជួបទូតមកពីប្រទេសឥណ្ឌានៅក្នុងស្រុកខ្មែរយើង។ទូតឥណ្ឌាឈ្មោះ**ចិនស៊ុន**។

*(នៅមានត)*

*លោក **ជន ឈានលី** ដកស្រង់ពីសៀវភៅ*

*អក្សរសាស្ត្រពុទ្ធសាសនានិពន្ធដោយលោក **យី ធន់***



# ចិត្តវិទ្យាអប់រំ

## មាតាបិតាពុំមែនជាតុលាការ ពុំមែនជាឆ្នាំគុក តែជាអ្នកនាំផ្លូវសម្រាប់បុត្រធីតា (ត)

- យើងជួបអ្នកដទៃចេះប្រើពាក្យសម្ដីផ្អែមល្ហែមបាន ដូចជាពាក្យសួរដោយសមគួរបែបសួរស្រទន់ថា៖ អ្នកអញ្ជើញទៅណា ឬមានការអ្វីដែរ? ហេតុអ្វីបានជាអ្នកធ្វើដូចនេះ? ព្រោះអ្នកចង់មានមិត្តភាពជាជាងមានសត្រូវ។ អ្នកមានចំណីឆ្ងាញ់គួរផ្ដល់ឲ្យទៅអ្នកដទៃឬក៏កូន។ រីឯសម្រាប់កូនវិញហេតុអ្វីក៏ថាមិនអាចផ្ដល់បាន ឬធ្វើមិនបាន តើគួរផ្ដល់ឲ្យនូវសម្ដីមានរសជាតិបែបណា ឬក៏ជូរចត់...។

យើងជួបអ្នកដទៃ ឬមិត្តភ័ក្តិ យើងចេះប្រើពាក្យពីរោះពិសា(ផ្អែមល្ហែម) រាក់ទាក់។ឧទាហរណ៍សម្លាញ់មានការងារអ្វីដែរ?បងឬប្អូនជួយធ្វើកិច្ចការនេះមួយឲ្យខ្ញុំផង?ខ្ញុំអរគុណអ្នកណាស់..។ល។

ខ្ញុំសួរទៅអ្នកវិញថា ហេតុអ្វីបានជានិយាយគួរសមព្រោះតែអ្វី?ព្រោះជាមិត្តភាព ជាពាក្យថ្លៃថ្នូរ គេពុំមែនជាសត្រូវ និងចង់បង្ហាញថាខ្លួនជាជនដ៏គាប់ប្រសើរ និងម្យ៉ាងទៀត គឺចង់បាននូវផលត្រឡប់វិញជាផលវិជ្ជមាន សមតាមបំណងប្រាថ្នា។

រីឯចំពោះកូនយើងវិញដូចម្ដេចដែរ? គួរត្រូវទទួលបាននូវពាក្យដ៏មានឱជារសទាំងនេះពីម្ដាយឪពុកឲ្យបានច្រើនជាងសម្ដីអសុរោះ ជាប្រចាំដែរឬទេ? ពាក្យសម្ដីអសុរោះកាន់តែតិច ហិង្សាលើរាងកាយកាន់តែថយ ពេលនោះទឹកមុខស្រស់ថ្លារបស់កូន ស្នាមញញឹមរបស់អ្នករីកស្រស់បំព្រងអារម្មណ៍ចង់តែជួបគ្នា មិនចង់ចាកឃ្លាត។

ខ្មាសអ្វី ខ្លាចអ្វី នឹងប្រើពាក្យទាំងនេះចំពោះបុត្រធីតាជាទីស្រឡាញ់ស្មើជីវិតទៅហើយនោះ។

មិនពិបាកយល់ទេ បើយើងបានអរគុណចំពោះកូន គឺកូននឹងចេះអរគុណចំពោះអ្នកវិញ។ ពាក្យអរគុណនេះ សូមកុំគិតថាប្រើបានតែចំពោះអ្នកដទៃ ប៉ុន្តែជាពាក្យប្រើគ្រប់វណ្ណភាព ពីទាបទៅខ្ពស់ និងពីខ្ពស់មកទាប។ ការពោលពាក្យអរគុណចំពោះកូន ពុំមែនជាអំពើឆ្គាំឆ្គងឡើយ។ ជាពាក្យថ្លៃថ្នូរ គួរគប្បីប្រតិបត្តិឲ្យខ្ជាប់ខ្ជួន និងទូលំទូលាយ នឹងនាំមកនូវប្រសិទ្ធភាពក្នុងការទំនាក់ទំនង ដែលផ្ដល់គុណប្រយោជន៍ក្រៃលែងក្នុងជីវិតរស់នៅ ពិសេសកាត់បន្ថយនូវភាពរើសអើង។ ប្រសិនបើកូនបានអរគុណចំពោះយើង ខណៈនោះអារម្មណ៍អ្នករំភើបស្រស់ស្រាយដូចម្ដេចដែរ? សូមកុំព្រងើយកន្តើយ ឬដោយមូលហេតុការងារ ឬព្រោះតែទុក្ខកង្វល់ណាមួយរបស់ខ្លួន គប្បីប្រញាប់ឆាប់ញញឹមតប ឬឆ្លើយតបភ្លាមថា **ល្អហើយកូន!** ដោយសម្ដីស្រទន់ កុំសើចតបវិញឲ្យសោះ ឬ ពោលពាក្យសម្ដីទាំងឡាយណាដែលនាំឲ្យកូនខ្មាស ឬសៅហ្មងចិត្ត។ ការសើចតប

វិញនេះ ជាប្រតិកម្មអវិជ្ជមានធំបំផុត ព្រោះថាអាចជាការចំអកធ្វើឲ្យកូនរៀនខ្មាស នឹងអាចថានៅពេលក្រោយអ្នកពុំទទួលបានពាក្យអរគុណនេះពីបុត្រធីតាទៀតឡើយ មិនតែប៉ុណ្ណោះគឺអ្នកនេះហើយជាអ្នកបន្ទច់បង្អាក់នូវអំពើល្អមួយនេះរបស់កូន។ យើងជាមាតាបិតាគ្រប់រូប ចង់បានណាស់នូវអំពើសុជីវធម៌ពីកូនចំពោះអ្នកដូចជាការគោរព ការសំពះ...ដែលកូនខ្លះធ្វើមិនបាន ឬមិនធ្វើ។ ហេតុនេះហើយអ្នកព្រះភិរម្យភាសា **អ៊ូ** ហៅ **ឧ៎ុយ** ចារចែងនៅក្នុងច្បាប់កេរកាលថ្មីថា៖

*"ម៉ែឪមានគុណណាស់ មិនសំពះខ្មាសរៀនដៃ*
*បើអ្នកក្រៅដទៃ វិស័យសោះសំពះបាន។"*

នេះមិនមែនបានន័យថា ត្រូវតែសំពះកូន ក៏ព្រោះតែចង់បានការសំពះពីកូននោះវិញទេ។ វាពិតជាមានជម្រើសយ៉ាងប្រាកដ សូមសិក្សាស្រាវជ្រាវអំពីសុជីវធម៌ខ្មែរយើង។

ឯការបង្គាប់កូននៅតូចដូចជាឲ្យចង្អុលមុខ ឲ្យស្តោះដាក់មុខ ឬជេរអ្នកនេះ ជេរអ្នកនោះ ឬបង្អកគ្រឿងស្រវឹង(ស្រាបៀរ) រួចហើយលោកអ្នកបែរជាសើចសប្បាយនៅពេលឃើញកូនធ្វើតាម ឬ ក៏ឲ្យសំបកកំប៉ុង/ដប ចាក់ស្រា ហុចសាច់ក្លែម... ដែលជាការបម្រើការទទួលទានគ្រឿងស្រវឹងរបស់លោកអ្នក ឬក៏នៅជិតលោកអ្នកកំពុងប្រព្រឹត្តល្បែងស៊ីសង... ដែលជាអំពើអបាយមុខ។ល។ អំពើនេះជាអំពើមិនគប្បី ផ្តាំផ្គង និងខុសទាំងស្រុងហើយ។

### **១.៥ កាយវិការអហិង្សា ឬសកម្មភាពស្និទ្ធស្នាល**

សកម្មភាពស្និទ្ធស្នាល ជាអំពើនៃកាយវិការ**អហិង្សា** ដោយហេតុអ្វី? ពីព្រោះអ្វី?

សកម្មភាពស្និទ្ធស្នាលអាចកើតទៅបានល្គឹកណាតែគ្មានភាព**ហិង្សា** ពិសេសបានយល់ចិត្តគ្នាដោយគោរពផង និងស្រឡាញ់ផង។

នៅពេលស្រឡាញ់នរណាម្នាក់ តើយើងត្រូវធ្វើអំពើដោយផ្ទាល់យ៉ាងដូចម្តេច?

- កាលបើលោកអ្នកមានពាក្យផ្អែមល្ហែមហ្មត់ហ្មងហើយ វានឹងស្តែងចេញនូវភាពស្និទ្ធស្នាលយកចិត្តទុកដាក់ ដែលជាអំពើប្រព្រឹត្តដោយកាយវិការផ្ទាល់។

ចំណែកបុត្រធីតាជាទីស្រឡាញ់របស់យើងវិញ តើគួរមាន**កាយវិការអហិង្សា** ឬការបបោសអង្អែលដោយផ្ទាល់ពីយើងជាម្តាយឪពុកយ៉ាងដូចម្តេច?

- លោកអ្នកមាននៅចង់ចាំឬទេ កាលកូនអ្នកប្រសូតចេញមកក្រោយពីសម្អាតហើយភ្លាមកូនត្រូវបានពេទ្យទាំងសម័យ ទាំងបុរាណយកមកឲ្យអ្នកជាមាតាបំបៅ ដោយផ្តេកផ្តិត ឱបស្និទ្ធស្និតនឹងដើមទ្រូង។ នេះជាអំពើការចងភ្ជាប់ចិត្ត ឬបង្កើតមនោសញ្ចេតនា ចាប់ពីថ្ងៃដំបូងសម្រាប់មនុស្សថ្មី(កូន) ដែលត្រូវមានជីវិតរស់រានលើភពផែនដីជាមួយយើង។ អំពើនេះ មានខ្លឹមសារប្រពៃ មានគុណតម្លៃរៀបរាប់មិនអស់។

ទង្វើនេះលើកឡើងដើម្បីឆ្លុះបញ្ចាំងអំពីការបង្កើតមនោសញ្ចេតនា គឺពុំបានតម្រូវឲ្យអ្នកជាមាតាធ្វើចំពោះកូនគ្រប់វ័យយ៉ាងនេះទេ។ លោកអ្នកពិតជាយល់ដឹងច្បាស់អំពីភាពស្និទ្ធស្នាលរបស់មាតាបិតាចំពោះបុត្រធីតា ដោយមិនភាន់ច្រឡំតាមអគតិ។

# ចលករសិក្សា

## I. សេចក្ដីផ្ដើម

អ្នកសិក្សាដែលអាចទទួលការសិក្សាបានប្រកបដោយប្រសិទ្ធភាពខ្ពស់ គឺនៅពេលណាដែលគេចង់រៀន។ ដូចនេះបញ្ហាដែលសំខាន់ និងចាំបាច់គឺ គ្រូបង្រៀនត្រូវធ្វើដូចម្ដេចឲ្យសិស្សចង់រៀន ឬសិស្ស "ត្រូវបានទទួលការជំរុញទឹកចិត្ត"។

## II. វត្ថុបំណងនៃមេរៀន

- ជួយជំរុញអ្នកសិក្សាឲ្យយល់ពីបញ្ញត្តិចលករសិក្សា។
- បង្ហាញពីសារៈសំខាន់នៃចលករសិក្សានៅក្នុងលំនាំបង្រៀន និងរៀន។

## III. និយមន័យ

- ចលករ គឺអ្វីដែលធ្វើឲ្យបុគ្គលចាប់ផ្ដើមធ្វើការងារ។
- ចលករ គឺជាអ្វីដែលធ្វើឲ្យមនុស្សបន្តធ្វើការងារអ្វីមួយ។
- ចលករ គឺការចង់ដឹងពីអាកប្បកិរិយា (ដោយពេញចិត្ត)។
- សមត្ថភាព គឺការអាចនៃអាកប្បកិរិយា (ដែលជាសក្ដានុពល)។

• មនុស្សត្រូវបានទទួលការជំរុញទឹកចិត្តដោយសារវត្ថុខុសគ្នា និង "ការចង់ដឹង" ដែលមានកម្រិតខុសៗគ្នា។

• ឋានានុក្រមតម្រូវការមាន ៥ក្រុម -តម្រូវការដើម្បីរស់ **(Survival Needs)** -តម្រូវការផ្នែកសន្តិសុខ និងសុវត្ថិភាព **(Safety and Security Needs)** -តម្រូវការផ្នែកសង្គម **(Social Needs)** -តម្រូវការលើកសរសើរ និងការគោរពខ្លួនឯង **(Esteem and Self-respected Needs)** -និង តម្រូវការធ្វើឲ្យខ្លួនឯងមានលក្ខណៈពិតប្រាកដ **(Self-actualization)** ។

• តម្រូវការគឺជាការទាមទារនូវអ្វីមួយដែលនៅខាងក្រៅខ្លួនបុគ្គល។ អ្វីនោះអាចជាវត្ថុ ឬ អ្នកផ្សេង។ តម្រូវការ គឺជាប្រភពនៃចរិតសកម្មរបស់សកម្មភាព។ សកម្មភាព ធ្វើឲ្យតម្រូវការថ្មីលេចឡើង និងមានការលូតលាស់។ ភាពសម្បូរបែបច្រើនរូបភាពខុសៗគ្នានៃតម្រូវការចំណុះភាពសម្បូរបែប និងច្រើនរូបភាព ព្រមទាំងឲ្យស្របនឹងវ័យជាកំណត់របស់បុគ្គលនោះ។

• ពេលណាការយល់ដឹងពីអត្ថន័យនៃតម្រូវការចំពោះអត្ថិភាព និងការលូតលាស់របស់បុគ្គលកាន់តែគ្រប់គ្រាន់និងស៊ីជម្រៅ ពេលនោះតម្រូវការនឹងក្លាយជាកម្លាំងជំរុញបុគ្គលនោះឲ្យធ្វើសកម្មភាព ដើម្បីសម្រេចគោលបំណងនៃការបំពេញតម្រូវការនេះបានដោយពិតប្រាកដ។

## IV. ប្រភេទចលករសិក្សា

### ១.ចលករសិក្សាអាចជាចលករវិជ្ជមាន និងអវិជ្ជមាន

### ១.១ ចលករសិក្សាវិជ្ជមាន (គោលបំណងវិជ្ជមាន)

✦<u>ការលើកសរសើរ</u>

ការលើកសរសើរប្រកបដោយលទ្ធផលខ្ពស់ គឺការលើកសរសើរពីស្មារតី។ អ្នកត្រូវបានលើក

សរសើរមានជំនឿជាក់ក្នុងការងារនិងទទួលបាននូវការយកចិត្តទុកដាក់ការគោរពពីអ្នកនៅជុំវិញ។ ប្រសិនបើលោកជាគ្រូបង្រៀនចេះចាត់តាំងការលើកសរសើរបានល្អនោះ ការលើកទឹកចិត្តនឹងទទួលបានប្រសិទ្ធភាពខ្ពស់។

ក្នុងការជាក់ស្តែងលោកអាចគួបផ្សំរវាងរូបភាពពីរ គឺការលើកសរសើរ និងជូនរង្វាន់ដល់បុគ្គលដែលអាចសម្រេចការងារយ៉ាងវិសេស ឬបុគ្គលដែលមានគំរូកម្រិតផ្ដើម។

លើការចាត់តាំងការលើកសរសើរ លោកត្រូវដាក់សំណូមពរជាចំហ និងជូនរង្វាន់ដល់បុគ្គលដែលបានសម្រេចការងារយ៉ាងវិសេស ឬបុគ្គលដែលមានគំរូកម្រិតផ្ដើម។

លើការចាត់តាំងការលើកសរសើរ លោកត្រូវដាក់សំណូមពរជាចំហ និងមានអត្ថន័យអប់រំជ្រាលជ្រៅទូលំទូលាយ។ ប្រសិនបើសមិទ្ធផលការងារទាប ហើយត្រឡប់ជាមានកម្រិតលើកសរសើរខ្ពស់នោះ គឺធ្វើឲ្យមនុស្សដែលត្រូវបានលើកសរសើរមានការពេញចិត្តចំពោះខ្លួន ដោយគិតថាខ្លួនគ្រប់គ្រាន់ពេញលេញហើយ។ ប្រសិនជាសមិទ្ធផលការងារខ្ពស់ត្រឡប់ជាត្រូវលើកសរសើរកម្រិតទាបនោះ អាចបង្កឡើងនូវអាស្មិមានះ ចិត្តស្រាល ឆាប់ខឹង មិនសប្បាយចិត្តបង្កឡើងនូវការថយចុះចរិតសកម្ម ក្នុងការធ្វើសកម្មភាព។

*ការលើកសរសើរ* គឺជាការទទួលយកសមិទ្ធផលសកម្មភាពក្នុងរយៈពេលកន្លងមក ព្រមគ្នានឹងសេចក្ដីសោមនស្សរីករាយរបស់មនុស្សទាំងអស់ដែលនៅជុំវិញ និងជាការជំរុញឲ្យឈានទៅអនុវត្តភារកិច្ចបន្តដែលមានកម្រិតកាន់តែខ្ពស់និងកាន់តែលំបាក។ ហេតុនេះ លោកត្រូវយកចិត្តទុកដាក់លើកសរសើរអ្នកខិតខំប្រឹងប្រែងពីកម្រិតទាបទៅកម្រិតខ្ពស់។

*គម្លាតរយៈពេល* ពីពេលដែលមានទង្វើគួរត្រូវបានលើកសរសើររហូតដល់ពេលលើកសរសើរកាន់តែខ្លី កាន់តែប្រកបដោយប្រសិទ្ធភាពខ្ពស់ "ប្រតិកម្មឆ្លើយតបយ៉ាងសកម្មចំពោះការប្រព្រឹត្តរបស់មនុស្សកាន់តែឆាប់ពេលណាលទ្ធផលកាន់តែខ្ពស់ពេលនោះ"។

✦**រង្វាន់** : គឺជាវត្ថុលើកទឹកចិត្តដ៏សំខាន់នៅក្នុងលំនាំគ្រប់គ្រង និងលំនាំបង្រៀន និងរៀន។

**រង្វាន់មានច្រើនបែប** :

- ការបង្ហាញពីការយល់ព្រមទទួលយកលទ្ធផលរបស់ការងារ។
- ការជូនរង្វាន់ចំពោះការងារដែលធ្វើបានល្អ (ថវិកា ឯកសារមានតម្លៃសម្ភារសិក្សា សម្លៀកបំពាក់...)។
- ការផ្ដល់បុព្វសិទ្ធិពិសេសចំពោះអ្នកដែលបានទទួលពិន្ទុវាយតម្លៃខ្ពស់។
- ការលើកឈ្មោះដាក់ក្នុងតារាង (បញ្ជី) កិត្តិយស។
- ការលើកបង្ហាញពីការងារល្អនៅចំពោះមុខអង្គប្រជុំនៅក្នុងសាលាទាំងមូល ឬ នៅចំពោះមុខសិស្សទាំងអស់នៅក្នុងថ្នាក់។
- ផ្ដល់ប័ណ្ណសរសើរ លិខិតសរសើរ ឬនិមិត្តសញ្ញាកិត្តិយស។
- ផ្ដល់មូលវិចារប្រកបដោយអត្ថន័យជ្រាលជ្រៅនៅក្នុងសំណុំឯកសារផ្ទាល់ខ្លួនបុគ្គល។

(*នៅមានត*)

*លោក* ***ជ័យ សយ្យនា*** *ដកស្រង់ពីឯកសារនាយកដ្ឋានបណ្ដុះបណ្ដាល*

# កុមារឈ្លាសវៃព្រោះបានធ្វើសកម្មភាពរៀន

នៅពេលដែលគេសួរលោកថា ហេតុអ្វីបានជាខួរក្បាលលោកពូកែ រូបវិទូ **អាល់ប៊ែរអាញស្តាញ** (Albert Einstein) បានឆ្លើយថា "ខួរក្បាលខ្ញុំមិនពូកែទេ តែខ្ញុំពូកែប្រើខួរក្បាល"។ ចម្លើយនេះគ្រប់គ្រាន់ល្មមឲ្យយល់បានថាមនុស្សណាក៏អាចឈ្លាសវៃបានឲ្យតែគេចេះប្រើខួរក្បាលឲ្យធ្វើការ។

មនុស្សទូទៅជឿថា ភាពឈ្លាសវៃរបស់មនុស្សគឺជាអំណោយពីធម្មជាតិ។ មនុស្សខ្លះកើតមកក៏មានប្រាជ្ញាលើសគេលើសឯង ឯមនុស្សខ្លះទៀតកើតមកល្ងង់រាប់ដប់មិនគ្រប់។ ការគិតបែបនេះពិតជាមិនត្រឹមត្រូវ ទោះបីជាមិនខុសទាំងស្រុងក្តី។ វាអាចនឹងមានមនុស្សដែលមានខួរក្បាលមិនល្អពីកំណើតដោយមូលហេតុនៃការប្រព្រឹត្តិខុសឆ្គងរបស់ស្ត្រីជាម្តាយនៅពេលដែលមានផ្ទៃពោះប៉ុន្តែក្នុងករណីធម្មតាមនុស្សមានខួរក្បាលប៉ុនគ្នា អាចនឹងវិវត្តទៅរកភាពឈ្លាសវៃដូចៗគ្នា។

ខួរក្បាលដូចជាសាច់ដុំដូច្នោះដែរ។ សាច់ដុំដែលត្រូវបានប្រើប្រាស់ជាអចិន្ត្រៃយ៍គឺជាសាច់ដុំដែលពូកែ ផ្ទុយទៅវិញ ប្រសិនបើទុកវាចោលមិនបានប្រើប្រាស់ មិនឲ្យវាធ្វើលំហាត់ទេវានឹងចុះខ្សោយ។ ខួរក្បាលដែលមិនត្រូវបានប្រើប្រាស់ឲ្យអស់សមត្ថភាពមិនឲ្យធ្វើការខ្លាំង មិនឲ្យវាធ្វើលំហាត់វាក៏មិនពូកែ។ លំហាត់សំរាប់ខួរក្បាលគឺកិច្ចការដែលពិបាក កិច្ចការដែល តម្រូវឲ្យមានការគិត។ កិច្ចការងាយៗ ដូចជាការទន្ទេញចាំមាត់ ឬការចម្លងអត្ថបទចេញពីសៀវភៅសិក្សាគោល ឬការចម្លងនូវអ្វីដែលគ្រូសរសេរនៅក្តារខៀន ឬការឆ្លើយនូវសំនួរដែលមានចម្លើយស្រាប់ក្នុងសៀវភៅនោះមិនធ្វើឲ្យខួរក្បាលធ្វើការ មិនមានឱកាសនឹងប្រែក្លាយខួរក្បាលឲ្យពូកែបានទេ។ ប្រភេទនៃលំហាត់ដែលខួរក្បាលត្រូវការគឺ *ការគិត* ។ វាមិនត្រូវការគិតងាយៗទេ ព្រោះការគិតងាយៗមិនមែនជាលំហាត់ តែវាត្រូវតែជាការគិតជ្រៅ ការគិតដែលពិបាក។ ការគិតជ្រៅ ការគិតពិបាកគឺជាប្រភេទនៃការគិតដែលជួយឲ្យខួរក្បាលមានការលូតលាស់កាន់តែពូកែ កាន់តែរឹងមាំ។

ម្យ៉ាងទៀត ខួរក្បាលក៏ត្រូវការអាហារូបត្ថម្ភដែរ។ វាទទួលនូវថាមពលពីអាហារដែលយើងបរិភោគ និងពីអុកស៊ីសែនដែលយើងដកដង្ហើម។ ដូច្នេះការហូបអាហារល្អក៏សំខាន់ណាស់ដែរសំរាប់ខួរក្បាលមិនមែនសំរាប់តែការរីកលូតលាស់នៃរាងកាយរបស់យើងទេ។អាហារល្អមិនសំដៅទៅលើអាហារថ្លៃ អាហារដែលសំបូរជាតិសាច់ តែគឺជាអាហារដែលមានជីវជាតិ ជាអាហារដែលសំបូរដោយផ្លែឈើស្រស់ បន្លែស្រស់ សាច់និងត្រីខ្លះ និងស្ករ ខ្លាញ់ អំបិលតិចតួច។ អាហារប្រភេទនេះមិនពិបាករកទេនៅស្រុកយើង។ អាហារប្រចាំថ្ងៃរបស់ខ្មែរជាអាហារល្អណាស់សំរាប់ខួរក្បាល។

កុមារទាំងអស់សុទ្ធតែមានខួរក្បាលល្អដូចគ្នាលើកលែងតែកុមារខូចខួរក្បាល។ ប្រសិនបើខួរក្បាលរបស់គេត្រូវបានប្រើឲ្យធ្វើការខ្លាំងប្រកបដោយការគិតកម្រិតខ្ពស់ ការគិតពិបាក ការគិត

ជ្រៅ នោះពួកគេក៏អាចនឹងក្លាយជាអ្នកពូកែ អ្នកឈ្លាសវៃ ដូចគ្នា។ ប៉ុន្តែ ប្រសិនបើគ្រូបង្រៀនមានបុរេវិនិច្ឆ័យថា កុមារនេះមិនឈ្លាសវៃ ហើយឲ្យគេធ្វើតែលំហាត់ដែលងាយៗ លំហាត់ដែលមិនតម្រូវឲ្យមានការគិតនោះ ពួកគេក៏នឹងទៅជាកុមារដែលមិនឈ្លាសវៃរហូត ហើយក៏នឹងទទួលឈ្មោះថា ជាកុមារដែលល្ងង់ពីកំណើត។

ការរៀនដោយសកម្មគឺជាអាហារដ៏ល្អបំផុតសំរាប់ខួរក្បាល ដែលគ្រូអាចផ្ដល់ជូនសិស្សរបស់ខ្លួន។ គ្រូបង្រៀនគប្បីប្ដូរឥរិយាបថ ឈប់ឲ្យសិស្សទន្ទេញចាំមាត់ ឈប់ឲ្យសិស្សថាតាមចម្លងតាម ឈប់ឲ្យសិស្សធ្វើតែលំហាត់ងាយៗ តែឲ្យគេធ្វើលំហាត់ដែលពិបាក លំហាត់ដែលតម្រូវឲ្យគេប្រើខួរក្បាលគិតជ្រៅ គិតពិបាក គិតក្រៅប្រអប់ គិតបែបច្នៃប្រឌិត។ គរុកោសល្យវិទូសម័យទំនើបបានបង្ហាញនូវគោលវិធីដែលជួយឲ្យគ្រូបង្រៀនប្រើប្រាស់នូវវិធីដែលជួយឲ្យសិស្សរៀនកាន់តែសកម្ម រៀនដោយធ្វើសកម្មភាពទាំងរាងកាយ ទាំងខួរក្បាល។ គ្រូបង្រៀនគប្បីរួមគ្នាស្រាវជ្រាវរកវិធីថ្មីៗដែលជួយសិស្សឲ្យកាន់តែឈ្លាសវៃដោយប្រើប្រាស់ខួរក្បាលរបស់គេតាមវិធីរៀនដែលកាន់តែសកម្ម៕

*លោក* **អ៊ីវ សារីក់**

## កិច្ចរបស់កូនសិស្សប្រព្រឹត្តនឹងគ្រូ

ឪពុកម្ដាយបង្កើតរូបយើងមក ខំរកចិញ្ចឹមថែរក្សា
មិនដែលឲ្យយើងអត់អាហារ ទើបរស់ជីវ៉ារូបយើងនេះ។

ឯគ្រូបង្រៀនប្រៀនប្រដៅ មនុស្សខ្លៅទៅជាបានតម្រិះ
ឲ្យយើងរាល់គ្នាមានចំណេះ ទើបចេះដឹងជាមនុស្សល្អបាន។

ហេតុនេះឯខាងគ្រូអាចារ្យ បង្កើតប្រាជ្ញាយើងគ្រប់ប្រាណ
លោកខំបង្រៀនគ្មានស្រាកស្រាន្ត ចង់ឲ្យអ្នកបានល្អប្រពៃ។

គ្រូទុកដូចមាតានិងបិតា ត្រូវអ្នកស្នេហាជាប្រក្រតី
ដឹងគុណឲ្យស្មោះអស់ពីថ្លៃ បើលោកជេរស្ដីកុំបីខឹង៕

*(ស្រង់ពីទស្សនាវដ្ដីសិក្សា១៩៨១)*




# អំពីបញ្ហាស្រៈមួយចំនួនមិនរាប់ ដាក់បញ្ចូលទៅក្នុងក្រុមស្រៈនិស្ស័យ

## I. សាវតារ

ការសិក្សាអំពីស្រៈ បាលីថា "សរ" ភាសាសំស្ក្រឹតថា "ស្វរ" មានន័យថាជាអក្សរដែលអាចបញ្ចេញសំឡេងខ្លួនឯងបានផង អាចនាំព្យញ្ជនៈឲ្យចេញសំឡេងបានមានសូរពុតាមរំពងរបស់ព្យញ្ជនៈ។

ក្នុងការសិក្សាភាសាខ្មែរ ដើម្បីនិយាយនិងសរសេរឲ្យបានត្រឹមត្រូវ គឺត្រូវផ្អែកលើ"វេយ្យាករណ៍" (មានន័យថា ការធ្វើឲ្យជាក់ច្បាស់ ឲ្យប្រាកដ...) ដែលជាក្បួនបង្រៀនវិធីអក្ខរៈ ហើយក្បួននេះទៀតសោតត្រូវប្រារព្ធរៀបរៀងតាំងពីព្យញ្ជនៈ និងស្រៈឡើងទៅ។ ដូចជាអក្ខរៈ ឬ "អក្សរ" ឬហៅថា វណ្ណៈ គឺរាប់ទាំងស្រៈ និងព្យញ្ជនៈ។ ឯស្រៈមានពីរពួក ស្រៈពេញតួ និងស្រៈនិស្ស័យ។

## II. បញ្ហា

ឆ្លងតាមការសិក្សា តាំងពីយូរមកហើយ យើងឃើញថាការសិក្សាអំពីស្រៈនិស្ស័យនិង ស្រៈពេញតួយើងតែងឃើញថាមានបញ្ហាចោទជារឿយៗអំពី ការដែលកម្មវិធីសិក្សាពីមុនក៏ដូចបច្ចុប្បន្នមានការកំណត់ឲ្យសិស្សានុសិស្សរៀនអំពីស្រៈមានចំនួន និងរូបរាងខុសគ្នា។ ជាហេតុធ្វើឲ្យយើងឆ្ងល់និងចោទសួរថា តើស្រៈនិស្ស័យមានពិតប្រាកដប៉ុន្មានតួ? អ្វីខ្លះ? ហេតុអ្វីបានជាស្រៈ អិះ "មានសញ្ញាកត់សូរ" ិះ មិនដាក់បញ្ចូលទៅក្នុងចំណោមស្រៈនិស្ស័យដទៃផង? ចុះស្រៈ អុះ ស្រៈ អេះ និងស្រៈ អោះ (ស្រៈ ុះ េះ ោះ) ជាដើមយ៉ាងម៉េចដែរ? តើស្រៈនិស្ស័យមាន ២០ ២១ ២៣ ២៤ ឬ២៥តួ?

ពិតណាស់ថា នៅក្នុងកម្មវិធីសិក្សាបច្ចុប្បន្ននៅថ្នាក់ទី១ ២ និងទី៣ ឃើញស្រៈនិស្ស័យមានតែចំនួន ២៣តួទេរាប់ពីស្រៈ អា ដល់ស្រៈ អោះ (សញ្ញាកត់សូរ "ា-ោះ" ដែលក្នុងនេះមិនរាប់បញ្ចូលស្រៈ អ ជាស្រៈកប់តួ និងស្រៈ "អិះ" (ិះ) ដែលជាស្រៈផ្សំ ឬស្រៈបន្ថែមផង។

ហេតុនេះហើយដែលធ្វើឲ្យមហាជន ឬមតិសាធារណជនភាគច្រើនឆ្ងល់ចោទជាបញ្ហាច្រើន ដូចបានលើកឡើងខាងលើ ប៉ុន្តែទោះបីហេតុផលយ៉ាងណាក៏ដោយចុះ បើយើងក្រឡេកមើលឯកសារផ្សេងៗជាតឹកតាងក៏ឃើញថា អាចនឹងបញ្ជាក់ជូនសិស្សានុសិស្ស អ្នកសិក្សាស្រាវជ្រាវក៏ដូចជាមហាជនទូទៅស្រមៃខ្លះៗហើយដែលថាវាពិតជាមានសម្មតិកម្មខុសគ្នាពីឯកសារមួយទៅឯក-សារមួយ ពីកម្មវិធីសិក្សាជំនាន់មួយទៅជំនាន់មួយទៀតផងដែរ។ ជាទឡ្ហីករណ៍ចំពោះបញ្ហានេះ ខ្ញុំសូមសាកល្បងលើកករណីសិក្សាចំនួនពីរបីគ្រាន់ជាទីអាងនិងដើម្បីធ្វើការឆ្លុះបញ្ចាំងហើយវាយតម្លៃ ឬសន្និដ្ឋានដូចខាងក្រោម៖

១- តាមវចនានុក្រមខ្មែរ របស់**សម្តេចសង្ឃរាជជួន ណាត** លោកបានបង្ហាញថាស្រៈនិស្ស័យ (ស្រៈមិនពេញតួដែលព្យញ្ជនៈអាស្រ័យផង) មាន២១តួគឺ । ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ ដែលផ្សំនឹងព្យញ្ជនៈថា ក កា កិ កី កឹ កឺ កុ កូ កួ កើ កឿ កៀ កេ កែ កៃ កោ កៅ កុំ កំ កាំ កះ (ទំព័រ “ឌ”)។ ចំណែកទំព័រទី១៤៦២ លោកបានពន្យល់ថា ស្រៈសម្រាប់ប្រើក្នុងភាសាបាលីមាន៨តួគឺ អ អា ឥ ឦ ឧ ឩ ឯ ឱ។ ស្រៈសម្រាប់ប្រើក្នុងភាសាសំស្ក្រឹតមាន ១៣តួគឺ អ អា ឥ ឦ ឧ ឩ ឫ ឬ ឭ ឯ ឮ ឱ ឳ ថែមស្រៈឮ មួយទៀតជា១៤តួ។ សម្រាប់ប្រើក្នុងភាសាខ្មែរសម័យបច្ចុប្បន្ន រាប់ស្រៈផ្សំជាមួយនឹងនិគ្គហិត “o” និងវិសជនីយផងមាន ២១តួគឺ អ អា អិ អី អឹ អឺ អុ អូ អួ អើ អឿ អៀ អេ អែ អៃ អោ អៅ អុំ អំ អាំ អះ។ បើរាប់ទាំង ឫ ឬ ឭ ឮ ឮ ឪ ឱ ផង ២៨តួ ហើយស្រៈទាំងនេះបើលើកតែស្រៈ ឫ ឬ ឭ ឮ និងឪ ចេញ ចែកជា២យ៉ាងគឺស្រៈសុទ្ធដែលចេញសំឡេងតាមទំនើងខ្លួនឯងហៅថា “ស្រៈពេញតួ” (ត្រូវសរសេរពេញតួ) អ អា ឥ ឧ ឪ ឬ ឩ ឯ ឮ ឱ ឪ ។ អ អា ។ល។ អុំ អំ អាំ អះ (ចំពោះស្រៈ ឧ បុរាណសរសេរដាក់សញ្ញាត្រីសព្ទ “៊” ពីលើជា ឱ អានថា “អុក” ប៉ុន្តែសព្វថ្ងៃលែងប្រើហើយ (ប្រើ ឧក ដូចជា ឧកញ៉ា)។ ឯស្រៈមិនពេញតួដែលប្រើផ្សំជាមួយនឹងព្យញ្ជនៈហៅថា “ស្រៈផ្សំ” ត្រូវសរសេរគំនូសដូច្នេះ ា ិ ី ឹ ឺ ... ាំ ះ ផ្សំជា ក កា កិ កី កឹ កឺ...កាំ កះ ឬផ្សំជាមួយនឹងស្រៈ “អ” ពេញតួជា អ អា អិ អី អឹ អឺ...អាំ អះ ផងក៏បាន។ ដូចនេះក្នុងចំណោមស្រៈទាំងប៉ុន្មានខាងលើ យើងសង្កេតឃើញថា ពុំមានស្រៈ “អិះ” (ិះ) រាប់បញ្ចូលជាមួយផងទេ។ គឺមានតែនិគ្គហិត្ត “o” ដែលមានសណ្ឋានជាសូន្យមួយយ៉ាងរាប់ចូលជាព្យញ្ជនៈដែលមានសំឡេងដូចតួ “ង” ប្រកបក៏មាន ដូចតួ “ម” ប្រកបក៏មាន (សំស្ក្រឹតនិងបាលីរាប់និគ្គហិត នេះចូលក្នុងពួកព្យញ្ជនៈសេសវគ្គផងដែលអានថា អ័ង ឬអ័ម... (វចនានុក្រមខ្មែរសម្តេចជួនណាត ទំព័រ៥០៨) ឧទាហរណ៍មានស្រៈ អំ ជាដើម។ ចំណែកវិសជ៌នីយ “ះ” ដែលជាវណ្ណយុត្តមួយប្រភេទមានរូបបែបនេះ “ះ” (ហៅរះមុខក៏បាន) ខាងអក្សរទេវនាគរី (សំស្ក្រឹត) ប្រើជាចំណុចមួយគូលើក្រោមដូចយុគលពិន្ទុ (:) មានសូរសំឡេងស្រដៀងនឹងខ្យល់អក្សរ “ស” ដែលជាតួប្រកប ប៉ុន្តែមិនចេញសូរសម្ទស្សតាមប្រទល់ធ្មេញដូចតួ “ស” ទេ ដូចជាកន្លះ ពោះ សូរខុសគ្នានឹងកន្លាស់ ពស់។ហើយក៏មានពាក្យសំស្ក្រឹតដែលមានតួ “ហ” នៅខាងចុងបើផ្លាស់ “ហ” ជាវិសជ៌នីយ “ះ” ហើយគឺ មិនត្រូវប្រើតួ “ហ”ថែមទៀតទេ ដូចជា ពាក្យ គូហ ចន្ទ្រគ្រហ សំគ្រហ អនុគ្រហ ទៅជាគ្រឹះ ចន្ទ្រគ្រោះ សង្គ្រោះ អនុគ្រោះ បែបនេះវិញ (វចនានុក្រមខ្មែររបស់ សម្តេចសង្ឃរាជ ជួន ណាត ទំព័រ១២០១-១២០២)។ នេះសបញ្ជាក់ឲ្យឃើញថា ស្រៈនិស្ស័យ ដូចជា ស្រៈ

អឺះ ស្រះ អ៊ោះ នេះជាឧទាហរណ៍បញ្ជាក់ថាមានការប្រើប្រាស់ និងប្ដូរផ្លាស់តាមឥទ្ធិពលភាសាឬអក្សរសំស្ក្រឹត ទាក់ទងនឹងវិសជ៌នីយ "ះ" នេះឯង។ ដូចនេះករណី ស្រះ "អិះ" ក៏ជាឥទ្ធិពលនៃវិសជ៌នីយប្រើប្រកបនឹងស្រះនិស្ស័យដែរ។

សរុបមកយើងអាចនិយាយបានថាស្រះ "អិះ" (ិះ) ជាករណីស្រះបន្ថែម ឬអ្នកសិក្សាខ្លះនិយមហៅថាស្រះផ្សំ (ទោះបីពុំទាន់មានអ្នកវេយ្យាករណ៍ណាឲ្យឈ្មោះថាស្រះ "អិះ" (ិះ) ជាស្រះផ្សំ ឬ ស្រះបន្ថែមហើយក៏ដោយ)។ម្យ៉ាងការសិក្សាទៅលើពាក្យដែលប្រើប្រាស់ស្រះនេះក៏ពុំសូវជាសំបូរក្រាស់ក្រែលឯណាដែរ។

*(នៅមានត)*

*លោកស្រី* **ម៉ៅ តាន់ណាវី**

*អនុប្រធានការិយាល័យនៃនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា*

# កូន

កូនអើយកូនកើតមកពីម៉ែឪ កូនបានរស់នៅក្នុងលោកា
កូនរស់ព្រោះលោកថែរក្សា កូនគ្រប់រូបាឧស្សាហ៍គិត។

កូនមានសាច់ឈាមពុកម៉ែឲ្យ កូនកុំបណ្ដោយឆ្គោយគំនិត
កូនមានពុកម៉ែរស់នៅជិត កូនគួរប្រណិប័តន៍រាល់ថ្ងៃ។

កូនជាចរណៃថ្លៃជាងពេជ្រ កូនចាំងរំលេចដោយរស្មី
កូនមិនដឹងខ្លួនទេឬអ្វី កូនរស់រាល់ថ្ងៃព្រោះអ្នកណា។

កូនចូរដឹងចុះណាពិសី កូនរស់មានន័យល្អថ្លៃថ្លា
កូនរស់ព្រោះមានមាតាបិតា កូនត្រូវរក្សាអ្នកមានគុណ៕

*(ស្រង់ពីសៀវភៅ ដួងហឫទ័យនៃអ្នកមានគុណ)*

# ពិសោធប្រើប្រដាប់លេង និងសម្ភារឧបទេសសម្រាប់បុត្រធីតានិងសិស្ស (តចប់)

## ✦ តើក្មេងលេងបែបយ៉ាងណាខ្លះ?

កូនចៅយើងចូលចិត្តលេងណាស់ វាលេងជាមួយនឹងបងប្អូនវា ជាមួយនឹងមិត្រជិតខាងវា។ យើងឃើញស្រាប់ហើយ ក្មេងប្រុសវាមានកូនឡានមួយ វាស្រឡាញ់ណាស់ វាដេកឱប និយាយរកដូចឡាននោះមានជីវិត។ ក្មេងស្រីមានកូនក្រមុំកៅស៊ូ វាបំពេ វាឲ្យបៅ វានិយាយលួងលោម វាស្លៀកពាក់ឲ្យល្អ ដាក់ឲ្យដេកឲ្យបានស្រួល។ ក្មេងខ្លះទៀតមានកៅស៊ូមានគ្រាប់ដប....កាន់នៅជាប់នឹងដៃវា។ របស់ទាំងនេះហើយជាមិត្រប្ដូរជីវិតរបស់វា។ មនុស្សធំជាសត្រូវទី១នឹងក្មេងព្រោះចេះតែហាមឃាត់វាមិនឲ្យលេងល្បែងទាំងនោះ។

យើងសង្កេតមើលកូនអ្នកជិតខាង វាបោចសក់ម្ដាយវា វាចាប់កាន់របស់នេះរបស់នោះគ្មានឈប់ឈរ។ ជីដូនវាកំពុងដេរ វាចាប់ខ្សែរ ចាប់កន្ត្រៃ ទាញសំពត់ ទាញអំបោះ។ ការក្មេងធ្វើនេះឥតបានសម្រេចទេព្រោះម្ដាយវាក្ដី ជីដូនវាក្ដី ចេះតែឃាត់ឃាំង ចាប់យកចេញ ហាមប្រាមនិយាយសំដីបោះបោក។

ការដែលក្មេងចង់ចាប់កាន់របស់អ្វីមួយនោះ គឺចង់បំពេញបំណងដែលវាបានឃើញ ដើម្បីឲ្យដឹងច្បាស់នូវវត្ថុទាំងនោះ។ ជួនកាលក្មេងយករបស់នោះទៅដាក់ក្នុងមាត់ ព្រោះវាចង់ដឹងរសជាតិ។ បើកូនយើងឬសិស្សយើងមានការចង់ដឹង និងយល់បែបនេះ យើងកុំបីហាមឃាត់ឲ្យហួសហេតុពេក។ គឺជាឱកាសល្អហើយដែលយើងគប្បីពន្យល់អំពីគ្រោះថ្នាក់ ឬហេតុការណ៍កើតឡើងអំពីរបស់ទាំងអស់នោះឲ្យវាបានយល់។ តែកាលណាបើយើងចេះតែហាមមិនចេះចប់ នេះហាមនោះហាម នោះឃាត់ កូនឬសិស្សយើង នឹងទៅជាមនុស្សមួយទន់ខ្សោយដល់ទៅអនាគត ហើយការរស់របស់វានឹងពិបាកប្រព្រឹត្តនៅក្នុងសង្គមមនុស្ស។ ក្នុងផ្នែកអប់រំកូនចៅ ឃើញថាពុំសមរម្យដែរព្រោះចេះតែហាមប្រាមហួសហេតុ។ កូនឬសិស្សយករបស់នេះ ស្រែកឲ្យថា ទេ! ទេ! កុំកាន់! កុំយក! កុំប្រើ! កុំទៅ! ។ ការនេះហើយ នាំឲ្យកូន ឬសិស្សយើងចេះឆ្លើយថា ទេ! ចំពោះកិច្ចការទាំងឡាយណាដែលយើងយល់ថាមានប្រយោជន៍ដល់វា។

ក្មេងវាចូលចិត្តបោះបោក បោះចោលរបស់នេះ របស់នោះទៅក្រៅផ្ទះ ឬក្រោមផ្ទះ វាចាក់ទឹកចេញពីធុង វាវាយបំបែកក្អម វាធ្វើគំនរខសរលំដួល វាបានចោលដបទឹកដោះទៅដី វាធាក់ជាន់នំលេង។ ការប្រព្រឹត្តរបស់វាដូចនេះហើយ មនុស្សធំតែងតែខឹងនឹងវាជានិច្ច។ មានម្ដាយខ្លះ ឬបងខ្លះមានការវាយដេរក្មេងតូចៗនេះជាញឹកញយ។ ការប្រព្រឹត្តទាំងនេះគឺការសប្បាយរបស់វា ព្រោះជួនកាលវាល្បងកម្លាំងវា ឬប្រព្រឹត្តកីឡាតាមសភាពវា ជួនកាលវាធ្វើត្រាប់តាមអ្នកដទៃខ្លះដែលវាបានឃើញហើយជាប់ចិត្ត។ ការធ្វើបែបនេះវាគ្មានគំនិតថាជាការបំផ្លាញឡើយ។ ដល់ពេលក្រោយវានឹងមានគំនិតស្ដាបនាឡើងវិញ។ ត្រង់នេះយើងគប្បីប្រុងប្រយ័ត្នទៀតក្នុងការហាមឃាត់ក្មេងលេង បែបនេះ ព្រោះវាចា ឬអំពើទាំងឡាយរបស់មនុស្សធំជាថ្នាំពុលដល់ក្មេង។ ដូច្នេះយើងត្រូវរៀបចំ សម្ភារៈ និងទីកន្លែងឲ្យស្រួលដល់វាឲ្យលេងដោយសេរី។

## ✧ ប្រដាប់លេងត្រូវទុកដាក់ឲ្យមានរបៀប

ប្រដាប់លេងទាំងឡាយ ដែលក្មេងលេងនៅរាយពាសពេញទីល្វែងផ្ទះ គួរតែរៀបចំទុកដាក់ឲ្យបានរៀបរយស្រួលឡើងវិញ។ ការរៀបចំនេះជាប្រភពមួយត្រូវពិភាក្សាគ្នាយ៉ាងពិបាកបំផុត រវាងមាតាបិតានិងបុត្រធីតា។ការរៀបចំនេះជាហេតុការណ៍មួយនាំឲ្យក្មេងស្រែកយំនឹងខឹងសំបា ហើយនិងមានគំនុំគុំគួនយ៉ាងសម្ងាត់ផង។ មានមាតាបិតាជាច្រើនពេញចិត្តណាស់នឹងកូនដែលប្រដៅបាន ព្រោះវាបានរៀបចំប្រដាប់លេងរបស់វាដោយមានរបៀបកាលបើវាលេងរួច។ ជួនកាលកូនយើងប្រព្រឹត្តតាមហើយ តែការនោះមកពីមាតាបិតា ឬអ្នកអប់រំបានប្រដែប្រដៅដោយប្រើអំណាចផ្ដាច់ការដល់ល្បែងក្មេងតូចៗលេងជារៀងរាល់ថ្ងៃ។ អំពើនេះហើយបានបំផ្លាញការសប្បាយ ការស្រឡាញ់ ការនឹកមមៃរបស់វា ដែលខិតខំធ្វើឡើងក្នុងរវាង ២ឬ៣ ម៉ោងនោះ។

**អមរា** ជាក្មេងដែលមានចំណង់យ៉ាងខ្លាំង បានសង់ផ្ទះកំណើតរបស់វា ដោយផ្ចិតផ្ចង់ នឹងដុំឈើតូច។ វាបានរៀបចំសង់យ៉ាងយូរ ដោយគ្មានទៅលេងអ្វីទៀតឡើយ។ វាមានដាក់ដុំឈើធ្វើជាដើមដូង ដើមស្វាយ អណ្ដូងទឹក។ វាសប្បាយចិត្តណាស់នឹងឃើញការពិតនឹងភ្នែកវា។ វាសង្ឃឹមថានឹងបាននៅផ្ទះនេះដោយសប្បាយរីករាយ។ មួយរំពេចមក ពេលបាយមកដល់ដុំឈើ សម្ភារៈទាំងឡាយត្រូវគេរមួយកន្លែង ព្រោះគេយកតុរៀបចំអាហារសំរាប់គ្រួសារបរិភោគ។ ត្រង់នេះហើយគេឃើញតែទឹកភ្នែក និងខាំសង្កៀតធ្មេញរបស់កុមារនោះដែលវាបាត់បង់ផ្ទះរបស់វា។

ដោយយល់ហេតុដូចនេះ យើងគប្បីទុកកន្លែងកៀនកោះមួយផ្នែកតូច ទុកឲ្យកូនយើងលេងដោយសេរី។ កាលបើវាញ៉ាំបាយរួចហើយ វាត្រឡប់មកលេងនៅកន្លែងនេះវិញ។ វាអាចរុះរើដោយចិត្តវាហើយរៀបចំទុកដាក់ឲ្យស្រួលតាមកន្លែង។ ការសម្រេចចិត្តរើរំលាយល្បែងវាដោយដៃវា គឺមិនមានការសៅហ្មងអ្វីឡើយ ព្រោះវាចង់លេងនូវល្បែងផ្សេងវិញ។

ម្យ៉ាងទៀតគេឃើញម្ដាយខ្លះរៀបចំផ្ទះសំបែង តុ ទូ ជាញឹកញយ ហើយកូនស្រីគាត់តែងតែធ្វើត្រាប់តាមដោយសេចក្ដីរីករាយ។ បើម្ដាយនោះមានការរអ៊ូរទាំ ត្អូញត្អែរកូនក៏ត្អូញត្អែរដូចម្ដាយវាដែរនៅពេលលេងព្រោះវាធ្វើត្រាប់តាមម្ដាយ។បើម្ដាយដាក់កិច្ចការឲ្យកូនជួយធ្វើការរៀបចំផ្ទះសំបែងនោះកូនសប្បាយរីករាយណាស់ជួយធ្វើការម្ដាយដោយត្រឹមត្រូវ។ ក្នុងពេលនេះហើយ ម្ដាយត្រូវនិយាយពន្យល់អំពីប្រយោជន៍នៃសណ្ដាប់ធ្នាប់និងកិច្ចការប្រសើររបស់ជីដូនជីតាវាដែលប្រព្រឹត្តមកកាលពីគាត់នៅក្មេង។ កាលបើកូនមានចិត្តជាប់នឹងរបៀបរៀបរយនេះហើយក្នុងមួយជីវិតរបស់វា វានឹងចូលចិត្តប្រព្រឹត្តដូច្នេះតទៅ គ្រប់តែកិច្ចការ។

នៅក្នុងថ្នាក់រៀនខ្លះគេមានកង់ ដុំឈើ មានលាបពណ៌ មានរាងនិងទំហំផ្សេង។ គេមានធ្វើពីឈើនូវរាងបួនជ្រុង បួនជ្រុងទ្រវែង ត្រីកោណ ព្នាយស្រប រាងមូល រាងពងក្រពើ... ដាក់ឲ្យសិស្សលេងដើម្បីឲ្យត្រិះរិះដល់សណ្ដាប់ធ្នាប់នោះ។មានចំនួនល្បែងអប់រំជាច្រើនទៀត ដែលឲ្យក្មេងមានសណ្ដាប់ធ្នាប់ ដូចជាដុំឈើរៀបទៅមានចេញរូបភាពមួយយ៉ាងល្អ ដោយមានរូបដាក់ពណ៌យ៉ាងល្អនៅមុខខាងលើនៃដុំឈើកាត់នោះ។ ការលេងល្បែងបែបនេះជាញឹកញាប់ទៅ ក្មេងអាចធ្វើការនេះឲ្យបានឆាប់ហើយមានរបៀបផងនៅពេលយ៉ាងខ្លីបំផុត៕

*លោក* **ថែម ផាន**

# អំពីនិបាតស័ព្ទ និងអាយតនិបាត

❖ តើនិបាតស័ព្ទ (និ) និងអាយតនិបាត (អា.និ) មានន័យដូចម្ដេចហើយមានប្រយោជន៍យ៉ាងណាខ្លះ នៅក្នុងឃ្លាល្បះនៃភាសាខ្មែរ?

១- **និបាតស័ព្ទ** ជាស័ព្ទ ឬសូរសំឡេងសម្រាប់ផ្សំសម្ដីត្រង់ឃ្លាល្បះនីមួយៗ។ វាជាជំនួយឲ្យនាមស័ព្ទ គុណនាម និងកិរិយា ឲ្យមានសេចក្ដីស្រឡះច្បាស់លាស់ពីរោះស្រួលស្ដាប់។ ដូចពាក្យថា ក៏ (ក៏ដោយ ក៏ដែរ ក៏គ្មាន...) ក្ដី (ខ្ញុំក្ដី អ្នកក្ដី) ផង (ជួយគ្នាផង) ឯ (ឯលើ ឯខ្ញុំ...) បើ (បើមិនចេះទេ កុំធ្វើចេះ) គឺ (មិនចេះគឺល្ងង់ សម្រាន្ដគឺដេក)។ល។

២- **អាយតនិបាត** ដែលញែកឬវាតចេញឲ្យទូលាយទីបំផុតនៃនាមស័ព្ទដែលសម្រេចដោយវិភត្តិនាមស្រេចហើយ ឬពាក្យប្រែរបស់វិភត្តិនាម (ដំណើរបំបែកនាមស័ព្ទខាងភាសាបាលី និងភាសាសំស្ក្រឹតជាដើម។ ដូចពាក្យ រី (រីបុរសនោះ) នឹង (ទៅនឹងខ្ញុំ) ដែល (ការដែលខ្ញុំធ្វើ) ដល់ (ឲ្យទានដល់ស្មូម)។ល។

តទៅនេះ ខ្ញុំសូមលើកយក ពាក្យនិ និង អា.និ មួយចំនួនដែលមាននៅក្នុងវចនានុក្រមខ្មែរ និងក្នុងសៀវភៅសិស្សផ្សេងៗទៀតមកបង្ហាញដើម្បីពិចារណាក្នុងការប្រើប្រាស់វាឲ្យបានត្រឹមត្រូវក្នុងភាសាខ្មែរ។

+ ក៏ (និបាតស័ព្ទ (និ) ពាក្យជាសន្ធាន (ការចងភ្ជាប់) មានសំឡេងកញ្ឆក់ខ្លី សម្រាប់និយាយប្រយោគដោយឡែក) :

- អ្នកក៏ទៅ ខ្ញុំក៏ទៅ ។
- អ្នកធ្វើដូច្នេះក៏បាន ឲ្យតែអ្នកពេញចិត្ត។
- របស់នេះរូបក៏ល្អ តម្លៃក៏ថោក ។
- តម្រានេះគឺអាធំក៏ខូច អាតូចក៏ខាត
- តាព្រាហ្មណ៍បរិភោគបាយហើយ ក៏ចុះទៅផឹកទឹក ឯត្រពាំងទឹក ពស់វែកនឹងចឹកដៃព្រាហ្មណ៍នោះក៏នឹងស្លាប់ប្រាកដ។
- ឯសំពោច ក៏ឆ្លើយថា "អាជ្ញាក្ដៅណាស់នៅមិនបានទេ" ថាហើយក៏រត់ចូលព្រៃទៅ។
- ...ថាហើយ នៅចំពោះមុខព្រះឥសូរទីទុយក៏ធ្វើជាធ្មេចភ្នែកសំងំដេកបន្តិចទីទុយក៏ធ្វើជាភ្ញាក់ខ្លួន។
- អាឯង ក៏មិនលើកលែងគ្នា អញក៏មិនកោតក្រែងរិទ្ធិអំណាចអាឯងប៉ុន្មានដែរ។
- ខ្ញុំបានរួចជីវិតតែក្នុងគ្រានេះ ក៏ព្រោះមកបានជួប និងលោកជាអ្នកប្រាជ្ញ។
- ថ្ងៃក៏កាន់តែខ្ពស់ហើយអង្ករក៏ទទឹកអស់ថែមទៀត។
- កាលបើរាងកាយបានទទួលសេចក្ដីទុក្ខហើយចិត្តក៏រោលរាលអន្ទះអន្ទែងផងដែរ។

\+ ក៏នឹង ឬក៏នឹងបាន (និបាតស័ព្ទ)

\- ក្នុងបណ្ដាព្រះសង្ឃទាំងនោះ ប្រសិនបើមានអង្គខ្លះមិនអាចនឹងទ្រាំនៅក្នុងឋានៈជាបព្វជិតបាន ហើយសឹកទៅជាគ្រហស្ថ <u>ក៏នឹងបានទៅជា</u> ពលរដ្ឋជាតិខ្មែរអាចរាប់បញ្ចូលទៅក្នុងពួកប្រជាពលរដ្ឋចេះដឹងបានដែរ។

\+ ក៏ត្រូវ (និបាតស័ព្ទ)

\- ការប្រតិបត្តិដើម្បីឆ្ពោះទៅរកសេចក្ដីសុខខ្ពស់បំផុតតាមគោលការណ៍ព្រះពុទ្ធសាសនា <u>ក៏ត្រូវសិក្សា</u> ឲ្យស្គាល់គោលការណ៍នេះយ៉ាងច្បាស់លាស់ដែរ ទើបយើងអាចធ្វើដំណើរទៅមុខមិនវង្វេងផ្លូវ។

\+ ក៏ហាក់ដូចជា (និបាតស័ព្ទ)

\- ដោយគិតតែពីទំនុកបំរុងផ្គុងផ្ដើមខាងរាងកាយតែមិនគិតដល់ផ្លូវចិត្តផងនោះ <u>ក៏ហាក់ដូចជា</u> ជំរុញរាងកាយឲ្យចូលទៅដេកត្រាំនៅក្នុងកាមធាតុ។

\+ ក៏គ្មាន (និបាតស័ព្ទ)

\- លោកយាយជរានេះមានខ្លួនតែមួយ<u>កូនក៏គ្មានចៅក៏គ្មាន</u>

\+ ក៏អត់ (និបាតស័ព្ទ)

\- ក្នុងផ្ទះយាយជរានោះគ្មានអ្វីសោះ<u>ភ្លើងក៏អត់ទឹកក៏អត់</u>។

\- យុវជនកំសត់ម្នាក់នេះទ្រព្យ<u>សម្បត្តិក៏អត់</u> ចំណេះវិជ្ជាក៏អត់។

\+ ក៏បាន (និ)

\- ព្រះបាទអសោក (ស្ដេចឥណ្ឌា) ក្រោយដែលបានធ្វើសង្គ្រាមជាច្រើនឆ្នាំក្នុងកលិង្គរដ្ឋ <u>ទ្រង់ក៏បានយល់</u> ឃើញច្បាស់ថាសង្គ្រាមនាំឲ្យអន្តរាយដល់មនុស្សជាតិនិងបំផ្លាញទ្រព្យសម្បត្តិគ្រប់ប្រភេទ។

\- អ្នកនិពន្ធចិនច្រើននាក់មានលោកកាំង ថៃ ជាដើម<u>ក៏បានស្គាល់</u>សុវណ្ណភូមិនេះពិតណាស់។

\+ ក៏ដោយ (និ.ច្រើនប្រើនៅពីក្រោយពាក្យទោះ ឬទោះបី)

\- ទោះ<u>សើចក៏ដោយ</u> <u>យំក៏ដោយ</u> ខ្ញុំមិនខ្វល់ទេ។

\- ទីនេះ ទោះ<u>ស្រីក៏ដោយ</u> <u>ប្រុសក៏ដោយ</u> ចូលបានទាំងអស់គេមិនឃាត់ទេ។

\- អ្វីៗត្រូវតែប្រព្រឹត្តទៅនៅលើលោកយើងនេះទោះបីជាអំពើកុសល ឬអកុសល<u>ក៏ដោយ</u>។

\- ទោះក្នុងរជ្ជកាលណា<u>ក៏ដោយ</u> តាំងពីសម័យនគរភ្នំដល់ផុតសម័យអង្គរ ព្រះមហាក្សត្រជាពុទ្ធសាសនិកទាំងឡាយមិនដែលតាំងព្រះអង្គជាគូសត្រូវនឹងសាសនាដទៃដល់ម្ដងណាទេ។

(*នៅមានត*)

*លោក* **ទិត សៀង**

*អតីតសាលាស្ថាចារ្យទុតិយភូមិឆ្នាំ* 1972

# ការដាក់បញ្ចូលឯកសារ លើគេហទំព័រគ្រូ

*ដោយលោក អ៊ុក សម្ផស្ស និង កែល ការុណា កែសម្រួលដោយ សុក ថា នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន*

ក្នុងលេខមុន លោកអ្នកបានអានរួចមកហើយ អំពីរបៀបចុះឈ្មោះចូលជាសមាជិក ចូលប្រើប្រាស់លើគេហទំព័រគ្រូ (www.krou.moeys.gov.kh) ដើម្បីអាចធ្វើការដាក់បញ្ចូលឯកសារ ចែករំលែកដល់អ្នកសិក្សាស្រាវជ្រាវ លោកគ្រូអ្នកគ្រូ សិស្សនិស្សិត ក៏ដូចជាសាធារណជនទូទៅ ប្រើប្រាស់ដោយសេរី និងមិនគិតថ្លៃ ។

ក្នុងលេខនេះ យើងខ្ញុំនឹងបង្ហាញពីរបៀបដាក់ឯកសារលើគេហទំព័រគ្រូ ដោយអនុវត្តតាមជំហានដូចខាងក្រោម ៖

## ១. ចូលប្រើប្រាស់ក្នុងគេហទំព័រគ្រូ



*រូបភាព ១ ៖ អាសយដ្ឋានគេហទំព័រគ្រូ*

សូមចូលទៅកាន់គេហទំព័រគ្រូ www.krou.moeys.gov.khបន្ទាប់មកសូមចុចរបាររមូរចុះក្រោម (Scroll Bar) រហូតដល់ឃើញប្រអប់ **សមាជិក** ដែលស្ថិតនៅផ្នែកខាងស្ដាំ នៃគេហទំព័រ ។ បន្ទាប់មកសូមបំពេញឈ្មោះអ្នកប្រើ របស់អ្នក ចូលក្នុងប្រអប់ **ឈ្មោះអ្នកប្រើប្រាស់** និង ពាក្យសម្ងាត់ ក្នុងប្រអប់ **ពាក្យសម្ងាត់** រួចចុចលើប៊ូតុង **ចូលប្រើប្រាស់** ។ (*រូបភាព ២*)

១. បំពេញឈ្មោះអ្នកប្រើ របស់អ្នកក្នុងប្រអប់ **ឈ្មោះអ្នកប្រើប្រាស់**

២. បំពេញពាក្យសម្ងាត់ក្នុងប្រអប់ **ពាក្យសម្ងាត់**

៣. រួចចុចលើពាក្យ **ចូលប្រើប្រាស់**



*រូបភាព ២ ៖ ប្រអប់សមាជិក*

បន្ទាប់មកអ្នកនឹងឃើញផ្ទាំងមួយដូច(**រូបភាព ៣**) ខាងស្ដាំ ដែលបញ្ជាក់ថាអ្នកកំពុងចូលប្រើប្រាស់លើគេហទំព័រគ្រូ ។

## ២. ការបង្កើតអត្ថបទថ្មី

ដើម្បីធ្វើការស្នើដាក់អត្ថបទរបស់អ្នកក្នុងគេហទំព័រគ្រូ សូមចុចលើ បង្កើតអត្ថបទថ្មី ។ (*រូបភាព ៣*)

បន្ទាប់មកអ្នកនឹងឃើញផ្ទាំងដូចរូបខាងក្រោម ៖



*រូបភាព ៣ ៖ បង្ហាញថាអ្នកកំពុងចូលប្រើប្រាស់*




*រូបភាព ៤ ៖ ដំណើរការនៃការបង្កើតឯកសារថ្មី*

**ចំណាំ ៖** នៅពេលដែលអ្នកដាក់អត្ថបទក្នុងគេហទំព័រគ្រូរួចរាល់ហើយ អ្នកគ្រប់គ្រងគេហទំព័រគ្រូរក្សាសិទ្ធិធ្វើការត្រួតពិនិត្យខ្លឹមសារ និងលក្ខណៈបច្ចេកទេស មុនធ្វើការដាក់បង្ហោះជាផ្លូវការលើគេហទំព័រគ្រូ ។




# ការអប់រំបញ្ចូលគ្នា

(បទពាក្យប្រាំពីរ)

១. កុមារពិការទាំងប្រុសស្រី ទោះតូចធំក្ដីទទួលបាន
នូវការអប់រំទាំងប៉ុន្មាន មិនអាចខ្វះបានការនេះធំ ។

២. អប់រំបញ្ចូលគ្នា គឺថា កុមារពិការទាំងតូចធំ
រៀនសូត្រក្នុងថ្នាក់បានជួបជុំ សិក្សាសមរម្យជាមួយគ្នា ។

៣. សិស្សមិនពិការមិនរើសអើង ឥតលើកតម្កើងនូវខ្លួនវា
ធ្វើឫកធ្វើរាងធ្វើគ្រប់គ្នា ខិតខំកៀងកៀរៀនរួមថ្នាក់ ។

៤. សិស្សមានបញ្ហាមើលនៅមុខ គ្រូយកចិត្តទុកដោយស្មោះស្ម័គ្រ
ជួយបង្ហាញប្រាប់ឥតលៀមលាក់ សិស្សពឹងពំនាក់ត្រូវជួយផង ។

៥. សិស្សមានបញ្ហាចលនាដើរ គ្រូកុំសូវប្រើត្រូវចាំចង
ព្រោះខ្លួនគ្មាខ្សោយជួយមើលផង កុំគិតបែរខ្នងខ្លាចមានគ្រោះ ។

៦. ម្យ៉ាងទៀតឲ្យអង្គុយខាងគេ ងាយស្រួលម្ល៉េះទេ មិនទ្រគោះ
ប៉ះពារគេឯង បង្កឈ្លោះ វាចាពីរោះលើកទឹកចិត្ត ។

៧. ខ្លះអន់បញ្ញាគ្រូគួរថ្នៃ ជួយចាប់កាន់ដៃដោយអាណិត
សរសេរគូសវាសបានតាមចិត្ត កិច្ចការប្រុងប្រិតបានសម្រេច ។

៨. បើគ្រូមានចិត្តជួយកុមារ គ្រប់ៗពិការចិត្តប្ដូរផ្ដាច់
រៀនសូត្រនឹងគ្នាបានសម្រេច សូមផ្ដែផ្ដាំផ្ដាច់កុំហិង្សា ។

៩. ពេលលេងកម្សាន្តជាមួយគ្នា នៅគ្រប់វេលាទាំងសិក្សា
មិនមានទំនាស់រាល់បញ្ហា ធ្វើឲ្យកុមារមិនភ័យខ្លាច ។

១០. ពេលរៀនហៅសួរចំៗឈ្មោះ វាចាពីរោះមិនកោងកាច

ឆ្លើយខុសត្រូវក្តីផ្តល់អំណាច កុំអាងបន្លាចបាត់ក្លាហាន ។
១១. មានការអប់រំបញ្ចូលគ្នា ប្រមូលកៀងកៀវរស់សុខសាន្ត
រស់នៅរួមគ្នាគ្រប់ភូមិឋាន ប្រទេសសាន្តត្រាណជួបសុខា ៕

*ដោយលោក* ***ធីវ សុផល***
*នាយកសាលាបឋមសិក្សាដំរីយកទឹក*
*ស្រុកសំរោង ខេត្តតាកែវ*

## ស្រឡាញ់ល្បែងអុក

"គេចាក់ត្រី ចុះនាង ចុះគោល ចុះសេះ កាត់គ្នាព្រួសប្រះអុកគ្នាផ្ទងផាំង អង់គ្នាចុះឡើង បញ្ឆោតគ្នាចុះឡើង ខូចឬបែកនេះនោះចុះឡើង មួយសន្ទុះ ឈ្នះចាញ់គ្នា ឬស្មើគ្នា" ហោគិល។

លេងយូរឡើង ខ្ញុំគិតឡើង មើលគេលេងយូរឡើង ខ្ញុំគិតឡើង "គិតយូរៗទៅក្រៅពីសប្បាយ ខ្ញុំទៅជាអាណិត មិនមែនអាណិតអ្នកលេងខ្លះដែលឈ្នះចាញ់វាល់រយពាន់នោះទេ គេមានលុយទើបគេលេង តែអាណិតកូនទាំងឡាយដែលត្រូវគេឲ្យស៊ីគ្នា ឬដូរគ្នា ជាល្បែង ឬជាប្រដាប់សម្រាប់គេឈ្នះចាញ់ ហើយសើចហោទៅវិញ។ តើគេសប្បាយដោយឃើញកូនទាំងនោះប្រយុទ្ធគ្នាឬ? គេយកកូនទាំងនោះឲ្យប្រយុទ្ធគ្នា ដើម្បីគេសប្បាយឬ? ឱ! ល្បែងអុកដ៏សប្បាយ"។

ត្រីទាំងអស់១៦(កូនទាំងអស់៣២) ប្រយុទ្ធគ្នាយ៉ាងល្អមើលលើក្រឡា៦៤។ ត្រីទាំងឡាយកិលទៅមុខទាំងសងខាង រហូតទល់គ្នាជាប់ ដោយមិនអាចថយក្រោយបាន វៀរលែងតែពេលណាបានឡើងសក្តិជាត្រីបក។ គេដូចជាគិតសម្បើមណាស់ ទម្រាំកាត់សេះ កាត់ទូកមួយៗ ឬក៏ទំរាំលោះសេះ លោះទូកមួយៗនោះ ដល់គេកាត់ត្រី ឬដូរត្រី ឬលោះត្រីមួយពីរវិញវាជារឿងងាយធម្មតា និងផុយល្អក។

ប្រយុទ្ធម្តងៗ ទម្រាំឈ្នះចាញ់ ទូកអាចសល់ទាំងពីរ សេះអាចសល់ទាំងពីរ គោលអាចសល់ទាំងពីរ ចំណែកត្រី បូកទាំងសងខាង ជួននៅមិនដល់បួនប្រាំផងៈ ដើម្បីខុនមួយ ត្រីត្រូវស៊ីគ្នាលេង អស់ចំនួនបីភាគបួនយ៉ាងតិច៕

*សម្រស់ជីវិត សាស្ត្រាចារ្យ យុន ស៊្រុន (១៩៤៥-១៩៧៨)*

# ថ្វីបើខ្លាំងគង់ចុះចាញ់

(បទពាក្យប្រាំពីរ)

១. វីដាវមុតស្រួចសភ្លឺថ្លា    សាហាវហានហាដល់កម្រិត
ក៏គង់ចុះចាញ់ការតាំងចិត្ត    ចិត្តមុតមុតចិត្តជាងអ្វីៗ ។
២. វីស្មូរសម្រែកកងរំពង    ផ្ទុះឮរំលងទ្វីបពីរបី
ក៏គង់ចាញ់ប្រៀបមិនអាចស្ដី    សម្មាធិចីរកាលកន្លង ។
៣. វីឫកអំនួតអួតអាងខ្លាំង    សាច់ដុំកម្លាំងសាហាវផង
គង់ខ្លាចភាពស្ងប់ស្ងៀមហ្មត់ហ្មង    មិនតបតសងហៅអំណត់ ។
៤. វីចោរកំណាចកាចសាហាវ    លួចឆក់ប្រេវប្រាវរត់បែនបត់
គង់ខ្លាចប៉ូលិសដែលហ្មត់ចត់    ទាញកសង្កត់ដាក់ខ្នោះដៃ ។
៥. វីបទចម្រៀងពីរោះពេក    ស្ដាប់ទៅចិត្តត្រេកត្រអាលក្រៃ
ក៏គង់ចាញ់ប្រៀបពាក្យមានន័យ    ជំនឿប្រពៃពីដូនតា ។
៦. វីព្រះអាទិត្យភ្លឺខ្លាំងពេក    ជះច្រាលពេញមេឃភ្លឺហៅមហា
ក៏គង់ខ្លាចភ្លឺនូវវិជ្ជា    ជ្រៅជ្រះនានាក្នុងមណ្ឌល ។
៧. វីឫទ្ធិអំណាចពួកទេវៈ    ពូកែខ្លាំងជាក់គ្មានអ្វីទល់
ក៏គង់ចុះចាញ់យ៉ាងរក់រល់    ព្យាយាមយង់យល់ល្អអស្ចារ្យ ។
៨. វីការភូតភរមិនរើសមុខ    ភូតចោលភូតទុកច្រើនម្ដេចម្ដា
ក៏គង់ខ្លាចទៀងមិនមុសា    ទៀងផ្ទាញ់ប្រហារឲ្យទោរទន់ ។
៩. វីទ្រព្យសម្បូរហូរហៀរពេក    ទ្រព្យធំអនេកច្រើនពេកពន់
គង់ចាញ់នូវចិត្តលះបង់ធ្ងន់    លះបង់ចិត្តជន់លែងនឹកនា ។
១០. វីផ្កាក្រអូបឆ្ងួលឈ្ងុយឈ្ងប់    ទាំងថ្ងៃទាំងយប់គ្រប់វេលា
ក៏គង់ចាញ់កេរ្ដិ៍ឈ្មោះនាមា    សាយសព្វគ្រប់គ្រាច្រាសទាំងខ្យល់ ។
១១. វីក្លិនស្អុយឆ្អួលរមួលពោះ    ស្អុយខ្លាំងនាំឈ្លោះកើតខ្វាយខ្វល់
គង់ចាញ់ក្លិនឈ្មោះស្អុយរចល់    ម្ចាស់ស្លាប់លែងយល់ក៏នៅស្អុយ ។
១២. វីការចុះចាញ់អម្បាលមាណ    ចងចាំកុំខានមិនប្រថុយ
ជួយយើងឲ្យស្វាងមិនខកខុយ    ទុកជាតម្រុយរស់បានសុខ ៕

*លោក* **ឈា ឈឿន**



# ពុទ្ធសាសនានៅកម្ពុជា (ត)

ព្រះបាទហ្វាន់-ចេ-ម៉ុន តាមឯកសារចិនថា ប្រហែលជាខាងចុងគ្រិស្តសតវត្សទី២ ទ្រង់ជាព្រះរាជាកាន់ពុទ្ធសាសនាមានកិត្យានុភាពល្បីល្បាញ ស្របគ្នានឹងសិលាចារឹកខ្មែរមួយ ដែលចាស់ទុំបរមបុរាណជាងគេបង្អស់ នៅដែនដីអាស៊ីភាគអាគ្នេយ៍ គេហៅថា សិលាចារឹកវ៉ូកាញ់ ខេត្តញ៉ាត្រាំង។ លោកល្វី ហ្វីណូត៍ (Louis Finot) បានពិចារណាឃើញថា ទីឋានស្រុកវ៉ូកាញ់នេះកាលពីអតីតកាលមិនមែនជាដែនដីចម្ប៉ាទេ គឺជាសាមន្តរាជរបស់ប្រទេសនគរភ្នំ ។ សេចក្តីក្នុងសិលាចារឹកវ៉ូកាញ់នេះ នាំឲ្យយល់ថាព្រះបាទស្រីមារៈជាអ្នកកាន់ព្រះពុទ្ធសាសនា ទ្រង់យល់ច្បាស់នូវដំណើរអន្ទោលស្លាប់កើតនៃសត្វលោកក្នុងវាលវដ្តសង្សារ ទ្រង់ប្រកបដោយមេត្តាករុណាដល់សព្វសត្វហើយទ្រង់ត្រាស់បង្គាប់ឲ្យបរិច្ចាគព្រះរាជទ្រព្យព្រះអង្គធ្វើជាទានទុកជាសាធារណប្រយោជន៍ ហើយទីបំផុតទ្រង់ផ្តែផ្តាំទុកថា សូមព្រះរាជាសោយរាជ្យជាតំណាតទៅអនាគត ប្រតិបត្តិតាមព្រះរាជប្រកាសនេះ ដើម្បីជាប្រយោជន៍ដ៏ធំដល់សត្វលោក។

ការស្រាវជ្រាវដំណឹងព្រះពុទ្ធសាសនាតាមរយៈឯកសារផ្សេងៗជាច្រើន អាចឲ្យយើងយល់ច្បាស់ថា ព្រះពុទ្ធសាសនាបានចូលមកប្រតិស្ឋាននៅប្រទេសខ្មែរយើង តាំងពីកាលព្រះពុទ្ធសតវត្សទី៣ម្ល៉េះ ហើយសិលាចារឹកវ៉ូកាញ់ជាសក្ខីភាពកាន់តែច្បាស់ថែមទៀតថា ក្នុងរជ្ជកាលព្រះបាទស្រីមារៈ គ្រិស្តសតវត្សទី២ ពុទ្ធសាសនាបានចម្រើនលូតលាស់រុងរឿងណាស់ក្នុងប្រទេសខ្មែរយើង។

ពង្សាវតារចិន ជំនាន់រាជវង្សត្ស៊ី (Tsi) ក្នុងគ្រិស្តសតវត្សទី៥មានរឿងដំណាលថា "ព្រះរាជានគរភ្នំ ជាព្រះរាជវង្សនៃកៅណ្ឌិន្យទ្រង់ព្រះនាម ចូ-យេ៉-ប៉ា-ម៉ូ (ជ័យវរ្ម័ន) គឺព្រះបាទកៅណ្ឌិន្យជយវរ្ម័ន ទ្រង់ឡើងសោយរាជ្យក្នុង ព.ស. ១០២០ (គ.ស. ៤៧៨) ។ កាលដើមទ្រង់កាន់សាសនាព្រាហ្មណ៍ គោរពព្រះឥសូរ តែក្រោយមកទ្រង់កាន់ពុទ្ធសាសនាវិញ។ ក្នុងព.ស. ១០២៧ (គ.ស. ៤៨៤) ទ្រង់បានបញ្ជូនភិក្ខុ ណា-គា-ស៊ាង គឺភិក្ខុសាក្យនាគសេនៈជាតិឥណ្ឌា ឲ្យជាបេសកជនទៅកាន់រាជសំណាក់ព្រះចៅក្រុងចិន វូ-ទី ទ្រង់បានផ្ញើគ្រឿងបណ្ណាការទៅថ្វាយព្រះចៅក្រុងចិន គឺរូបនាគរាជមាស១ រូបដំរីធ្វើពីខ្លឹមចន្ទន៍ក្រស្នាស១ ព្រះស្តូប២ ធ្វើពីភ្លុក សំពត់២ ផាប់ ចានកែវពិទូរ្យ២

ថាសដាក់ស្លា១ធ្វើពីក្រាស (អណ្ដើកសមុទ្រ១ប្រភេទស្នូកមានពណ៌ថ្លា)។ កាលទៅជួបព្រះចៅក្រុងចិនហើយ ភិក្ខុសាក្យនាគសេនបានរៀបរាប់ពីស្ថានភាពនៅប្រទេសនគរភ្នំគ្រប់ប្រការ ថ្វាយជាព័ត៌មានដល់ព្រះចៅក្រុងចិន។ ចំពោះសាសនា ភិក្ខុនាគសេនថ្វាយព្រះពរថា ប្រទេសនគរភ្នំកាន់សាសនាព្រាហ្មណ៍ គោរពព្រះមហេស្វរៈ (ព្រះឥសូរ) ឯព្រះពុទ្ធសាសនាក៏ចម្រើនរុងរឿងណាស់ដែរ មានស្រមណ៍(សមណៈ)ច្រើនក្រៃលែង ចំណែកការប្រតិបត្តិព្រះពុទ្ធវចនៈក៏រឹតតែប្រពៃណាស់ទៀត។ លុះដល់ភិក្ខុនាគសេនត្រឡប់ទៅវិញ ព្រះចៅក្រុងចិនបានសុំឲ្យលោកនាំយកគ្រឿងបណ្ណាការទៅថ្វាយព្រះចៅនគរភ្នំវិញដែរ។ ក្នុងព.ស. ១០៤៦ (គ.ស.៥០៣) ព្រះបាទកៅណ្ឌិន្យជយវរ្ម័នបានបញ្ជូនរាជទូតម្នាក់ទៅកាន់សំណាក់ព្រះចៅក្រុងចិនទៀត គ្រានេះទ្រង់បាននាំគ្រឿងបណ្ណាការសុទ្ធតែជាផលិតផលប្រទេសទៅថ្វាយព្រះចៅក្រុងចិន គឺព្រះពុទ្ធរូបធ្វើពីផ្កាថ្មសមុទ្រនិងវត្ថុដទៃទៀតជាច្រើន" ។

ពង្សាវតាចិនបន្ថែមថា ព្រះបាទកៅណ្ឌិន្យជ័យវរ្ម័នបានបញ្ជូនភិក្ខុខ្មែរ២រូបឲ្យទៅប្រែព្រះត្រៃបិដកនៅប្រទេសចិន។ ព្រះថេរៈទាំង២អង្គនេះគង់នៅប្រទេសចិនក្នុងរវាងចុងគ្រិស្តសតវត្សទី៥ និងខាងដើមគ្រិស្តសតវត្សទី៦។ ព្រះថេរមួយអង្គនាម សេង-គា-ប៉ូល៉ូ គឺជាសង្ឃបាលោ កើតពី គ.ស. ៤៦០ លោកចេះភាសាច្រើន។ ព្រះចៅវូ ក្នុងរាជវង្សលាង គ.ស. ៥០៦ និមន្តលោកឲ្យជួយប្រែព្រះត្រៃបិដក។ លោកព្រះសង្ឃបាលធ្វើការនេះអស់រយៈពេល១៦ឆ្នាំ នៅក្នុងការិយាល័យមួយឈ្មោះ ហ្វូណន-ក្វាង ប្រែថា "ការិយាល័យប្រទេសនគរភ្នំ"។

ព្រះថេរៈខ្មែរមួយអង្គទៀតនាម ម៉ុន-តូ-ល៉ូ ឬ ម៉ុន-តូ-ល៉ូសេង គឺមន្ទ្រសេនៈ។ លោកនិមន្តទៅដល់រាជដំណាក់ព្រះចៅវូ ក្នុង ព.ស. ១០៤៧ (គ.ស. ៥០៤) ហើយបានព្រះរាជានុញ្ញាតឲ្យចូលធ្វើការប្រែព្រះត្រៃបិដកជាមួយព្រះសង្ឃបាល។ សេចក្ដីប្រែជាស្នាព្រះហស្ថនៃព្រះថេរទាំង២អង្គមានជាប់ព្រះនាមនៅក្នុងព្រះត្រៃបិដកចិនរហូតមកដល់សព្វថ្ងៃ។

ក្រៅពីប្រភពចិន យើងមានសិលាចារឹក២កន្លែងទៀតស្ដីពីសម័យនគរភ្នំនៅចុងគ្រិស្តសតវត្សទី៥ គឺនិយាយពីព្រះបាទកៅណ្ឌិន្យជយវរ្ម័ន។ សិលាចារឹកមួយនៅប្រាសាទ៥ល្វែង ស្រុកទឹកខ្មៅ ខេត្តព្រៃកប្បស្សី កម្ពុជាក្រោម។ មួយទៀតនៅអ្នកតាដំបងដែក ខេត្តតាកែវ។ ព្រះបាទកៅណ្ឌិន្យជយវរ្ម័នចូលទីវង្គតក្នុង ព.ស. ១០៥៧ (គ.ស. ៥១៤)។

ព្រះបាទរុទ្រវរ្ម័នឡើងសោយរាជ្យតពីព្រះបិតាក្នុងគ.ស. ៥១៤។ លុះបានឡើងសោយរាជ្យហើយ ទ្រង់ក៏បញ្ជូនរាជទូតទៅកាន់សំណាក់ព្រះចៅក្រុងចិនជាច្រើនដង។ រាជទូតដែលទ្រង់បញ្ជូនក្នុង ព.ស. ១០៨២ (គ.ស. ៥៣៩) បាននាំយកគ្រឿងបណ្ណាការ គឺសត្វរមាសព្រមទាំងផលិតផលរបស់ប្រទេសខ្មែរច្រើនទៀត ហើយបានក្រាបទូលព្រះចៅក្រុងចិនថា នៅប្រទេសនគរភ្នំមានព្រះសារីរិកធាតុ គឺសក់មួយសរសៃយ៉ាងវែង (៣ម៉ែត្រ?)។ លុះជ្រាបដំណឹងនេះហើយព្រះចៅក្រុងចិនក៏បញ្ជូនភិក្ខុ ចេ-យុន-ប៉ាវ ឲ្យតាមរាជទូតខ្មែរមកដណ្ដើមយកព្រះសារីរិកធាតុនោះបាត់ទៅរហូតតទ្បូវ។

*(នៅមានត)* *ដោយលោក* ***ជ័យ សយ្យនា*** *ដកស្រង់ពី*

*សៀវភៅ "ពន្លឺពុទ្ធសាសនា" រៀបរៀងដោយលោក* ***សោម ខន***

# ព្រលឹងជាតិ

## សេចក្ដីផ្ដើម

ខ្មែរយើងមានជំនឿសំយោគលើព្រលឹង ព្រហ្មញ្ញសាសនានិងពុទ្ធសាសនា។ ជំនឿសំយោគនេះបានឆ្លុះបញ្ចាំងតាមរយៈប្រពៃណីខ្មែរយើងជាអាទិ៍ប្រពៃណីក្នុងពិធីរៀបអាពាហ៍ពិពាហ៍ដែលខ្មែរយើងអនុវត្តលទ្ធិ ៖

- ព្រលឹងនិយម គឺសែនដូនតា កួចដៃ(កួចព្រលឹង)...
- ពុទ្ធនិយម គឺសូត្រមន្តចម្រើនព្រះបរិត្ត
- ព្រហ្មនិយម គឺក្រុងពាលី បង្វិលពពិល (ទៀនតំណាងលិង្គព្រះឥសូរ ពពិលរាងដូចស្លឹកពោធិ៍តំណាងយោនីព្រះនាងឧមា)...។

ក្នុងចំណោមជំនឿខាងលើ លទ្ធិព្រលឹងនិយមជាជំនឿដែលខ្មែរមានតាំងពីមុនអរិយធម៌ឥណ្ឌាចូលស្រុកទៅទៀត។

យើងអាចញែកព្រលឹងខ្មែរយើងជាបីពួកគឺ ព្រលឹងបុគ្គល ព្រលឹងខ្មោចដែលជាព្រលឹងអន្តរបុគ្គល និងព្រលឹងជាតិ។

**ព្រលឹងបុគ្គល** គឺជាព្រលឹងមនុស្សរស់ដែលជាមនុស្សខ្មែរម្នាក់ៗ។ ដូនតាយើងបានលើកឡើងថា មនុស្សខ្មែរមានព្រលឹងទាំងតូចទាំងធំដប់ប្រាំបួន។ នៅពេលជួបគ្រោះភ័យ ដូចជាជួបសត្វអសិរពិស សត្វសាហាវ ឬជួបអាសន្ន (គេដេញសម្លាប់ សង្គ្រាមរាំងជល់ ខ្មោចលង...) មនុស្សខ្មែរតែងភ័យលស់ព្រលឹង បាត់ព្រលឹងមួយចំនួនដែលទាមទារត្រូវតែធ្វើពិធីជញ្ជាត់ព្រលឹង (ហៅព្រលឹងឬអន្ទងព្រលឹង) មកបង្គ្រប់វិញ " ឱ! ព្រលឹងប្រាំបួនដណ្ដប់ត្រឡប់មកវិញ! " ហើយនៅពេលដែលព្រលឹងធំចេញបាត់លែងត្រឡប់វិញ គឺមនុស្សស្លាប់។ ពេលដេកលក់យល់សប្ដិ ព្រលឹងតូចនេះចេញពីខ្លួនមនុស្ស ពេលត្រឡប់មកវិញទើបភ្ញាក់ដឹងខ្លួន។ ខ្មែរយើងតែងប្រារព្ធពិធី កួចព្រលឹងរៀបបាយព្រលឹងពេលធ្វើពិធីមង្គលផ្សេងៗដូចជាហៅព្រលឹងក្នុងពិធីកោរជុក ហៅព្រលឹងនាគក្នុងពិធីបំបួសនាគ... ដើម្បីសិរីសួស្ដី ចម្រុងចម្រើនដល់អ្នកដែលត្រូវកោរជុក ឬអ្នកដែលត្រូវបំបួសនាគ។

**ឯព្រលឹងខ្មោច** ដែលជាព្រលឹងអន្តរបុគ្គល គឺជាព្រលឹងរបស់ពួកបុព្វការីជន ដែលបានស្លាប់ទៅហើយរួមមាន ៖

- ព្រលឹងអារក្ខ (ដូនតាដែលបានស្លាប់ទៅហើយ ព្រលឹងដូនតា ព្រលឹងជួរជំបូរ)។ គេតែងលៀងអារក្ខ សែនដូនតា សែនជួរជំបូរ ដើម្បីបានជាសះស្បើយពីជំងឺដម្កាត់នានា ឬបានសុខសប្បាយ មានសេរីសួស្ដី។

- ព្រលឹងមេបា គឺព្រលឹងដូនតា ដែលចាំត្រួតពិនិត្យវិន័យក្នុងការរស់នៅរបស់កូនចៅ។ បើកូនចៅធ្វើឲ្យខុសវិន័យ ខុសសីលធម៌គ្រួសារ "មេបាតែងកាច់" (ធ្វើឲ្យកូនចៅណាម្នាក់ឈឺ) ។ គេពុំដែលសែនមេបា សុំសិរីសួស្ដីទេ តែគេសែនមេបាដើម្បីសុំខមាទោសលើកំហុសឆ្គងដែលកូនចៅបានធ្វើឲ្យបានជាសះស្បើយវិញ។ មេបាមានបីប្រភេទ គឺមេបាចាស់ទុំ (ញាតិចាស់ទុំ តមសម្ដីគ្នា) មេបាក្រមុំកម្លោះ (ក្រមុំកម្លោះប្រព្រឹត្តខុសសីលធម៌កន្លងប្រពៃណី ទុំមុនស្រគាល) និងមេបាផ្កាប់មុខ (ផិតប្ដី)។

- ព្រលឹងគ្រូបាធ្យាយ ខ្មោចគ្រូបាធ្យាយដែលតែងនៅថែរក្សា សិស្សគណ។ បើភ្លេចគ្រូ ឬខុសត្រណមគ្រូ គ្រូធ្វើឲ្យឈឺ ភ្លេចភ្លាំងស្មារតី រហូតឆ្កួត ឬស្លាប់ក៏មាន។ ពិធីរំលឹកគុណគ្រូនេះមានទល់សព្វថ្ងៃដូចជា ៖ ថ្វាយបង្គំគ្រូ មុនពេលប្រដាល់ មុនពេលលេងល្ខោន (ហោមរោង) ជាដើម។

- ព្រលឹងអ្នកតា គឺព្រលឹងពួកមេដែលធ្លាប់គ្រប់គ្រងកូនចៅ ហើយដែលបានចាកឋានទៅហើយ បានដល់ពួកមេទ័ព មេកន្ទ្រាញ មេកុលសម្ព័ន្ធ... ដូចករណីអ្នកតាឃ្លាំងមឿង អ្នកតាដំបងដែក អ្នកតាមេស យាយម៉ៅជាដើម។ គេឡើងអ្នកតាដើម្បីសុំសេចក្ដីសុខ សុំទឹកភ្លៀង សុំឲ្យមានកូន...។

ក្រៅពីព្រលឹងមនុស្ស និងព្រលឹងខ្មោចខាងលើ យើងមាន**ព្រលឹងជាតិ**ថែមទៀត។

**តើអ្វីទៅជាព្រលឹងជាតិខ្មែរយើង?**

I. **និយមន័យ** : មានមតិច្រើនដែលឲ្យនិយមន័យប្លែកៗគ្នាលើព្រលឹងជាតិនេះ។

- តាមវចនានុក្រមខ្មែរ បោះពុម្ពលើកទី៥ ទំ.៧៩១ "ព្រលឹង" គឺដំណើរជីវិត ស្មារតី វិញ្ញាណ (បាត់ព្រលឹង = បាត់វិញ្ញាណ) ។ ដូចនេះព្រលឹងជាតិគឺវិញ្ញាណជាតិដែលពុំចេះសាបសូន្យ និងទ្រទ្រង់ជាតិឲ្យរស់ជានិច្ច។
- លោក លី សុវីរ អរិយធម៌ខ្មែរទាក់ទងនឹងអក្សរសិល្ប៍ ទំ.១៣០ "ព្រលឹង គឺជាស្នាមគំនូសដែលនៅជាប់អ្វីមួយ"។ ដូចនេះ "ព្រលឹងជាតិគឺស្នាមគំនូសដែលនៅជាប់នឹងជាតិ"។
- លោក សរ សារុន សង្គមវិជ្ជាខ្មែរ (វប្ប-អរិយធម៌ភាគ២)
  + ទំ.៦៦ បញ្ជាក់ថា "**បុគ្គល= សរីរៈ+ព្រលឹង, អក្សរសិល្ប៍= អត្ថបទ+ព្រលឹង, ជនជាតិ= ប្រទេស+ព្រលឹង**"។ "ព្រលឹងសម្គាល់ធាតុអរូបីម្យ៉ាងស្ថិតនៅក្នុងខ្លួនបុគ្គលទៀងទាត់មិនប្រែប្រួល ហើយជាខ្លឹមនៃបុគ្គល។ ព្រលឹងពុំចេះស្លាប់ទេ តែរូបរាងបុគ្គលស្លាប់។ ព្រលឹងអក្សរសិល្ប៍ជាខ្លឹមអក្សរសិល្ប៍ដែលពុំចេះស្លាប់ ព្រោះមានលក្ខណៈសច្ចៈសកល មិនស្ថិតនៅក្រោមកត្តានៃកាលអាកាស ហើយហាក់ដូចជាមានភាពបន្តទៅសម័យក្រោយទៀត" ដូចជាល្បើករបស់លោក ឡា ហុងតែន គតិលោករបស់សុត្តន្តប្រិជាអ៊ិន កំណាញ់ក្រៅតម្រា (ម៉ៅស្វិត) រឿងទុំទាវ...។
  + ទំ.៦៨ បង្ហាញថា "ព្រលឹងជនជាតិនីមួយៗសំគាល់នូវគំនិត មតិយោបល់ អាកប្បកិរិយា ជំនឿសាសនា ប្រពៃណី មនោគមវិជ្ជា ចំណាប់ចំណូលចិត្ត របបគ្រប់គ្រងសេដ្ឋកិច្ច ដែលទ្រទ្រង់នូវវប្បធម៌ អរិយធម៌ជាតិនោះហើយមានជីវិតបន្តពីសម័យមួយទៅសម័យមួយទៀត"។

ខ្ញុំយល់ថា “**ព្រលឹងជាតិ គឺអ្វីៗដែលមិនចេះសាបសូន្យរបស់ជាតិ ហើយទ្រទ្រង់ជាតិឲ្យរស់បន្តទៀត ឬព្រលឹងជាតិគឺជាអត្តសញ្ញាណជាតិដែលមិនចេះសាបសូន្យនិងទ្រទ្រង់ជាតិឲ្យរស់ជានិច្ច**”។

II. **ព្រលឹងជាតិតាមទស្សនៈនានា**

មកទល់ពេលនេះ (២០១៦) ពុំទាន់មានការឯកភាពគ្នារវាងសង្គមវិទូនានាថាអ្វីខ្លះជាព្រលឹងជាតិខ្មែរនៅឡើយទេ តែមានត្រឹមជាទស្សនៈផ្ទាល់ខ្លួនឬជាការសិក្សាសាកល្បងរបស់រៀមច្បងយើងតែប៉ុណ្ណោះ។ នេះជាតួនាទីរបស់យើងនិងប្អូនៗជំនាន់ក្រោយជាអ្នកសិក្សាបន្ត។

1. អ្នកស្រី ត្រឹង ងា,អរិយធម៌ខ្មែរ ទំ.១២៣ ពន្យល់ថា “អរិយធម៌ខ្មែរជាព្រលឹងជាតិខ្មែរ”។
2. លោក រស់ ចន្ទ្រាបុត្រ,ប្រវត្តសាស្រ្តខ្មែរភាគ១,អារម្ភកថា បង្ហាញថា “ប្រវត្តសាស្រ្តនិងវប្បធម៌ជាព្រលឹងជាតិខ្មែរ”។
3. លោក លី សុវីរ,អរិយធម៌ខ្មែរទាក់ទងអក្សរសិល្ប៍ ទំ.១៨៥ បានលើកពី “ព្រលឹងមេបា” (មេ=នាងគង្ហីង=តំណាងដី,បា=ក្រពើ=តំណាងទឹក) ថាជាព្រលឹងជាតិ។
4. លោក សូ មុយឃៀង ទិត សៀង ជា ឈិន,អរិយធម៌ខ្មែរ ទំ.២១ ដល់២៣ បានលើកឡើងថា ខ្មែរមាន “ព្រលឹងមេបា ព្រលឹងដូនតា ព្រលឹងជួរជំបូរ ព្រលឹងគ្រូបាធ្យាយ”។
5. លោក ងួន ញ៉ិល ក្នុង “ព្រលឹងមាតាធិបតេយ្យក្នុងសង្គមខ្មែរ” ក៏លើកថា “មេនិយមជាព្រលឹងរបស់ខ្មែរដែរ ដោយបញ្ជាក់ថា ស្រ្តីជាធំ ជាមង្គលគ្រួសារនិងសង្គម”។
6. លោក សរ សារុន សង្គមវិជ្ជា ទំ.៧៤ ដល់១១៥ បានខិតខំសិក្សា និងពន្យល់ថា “ព្រលឹងជាតិខ្មែររួមមាន ៖ មាតាធិបតេយ្យ កម្លាំងការពារ (កំលាំងស្នេហាជាតិ កំលាំងវីរភាព) ភាពមានអំនួត កសិកម្ម ការពុំសូវចេះគោរពច្បាប់ ភាពអសកម្ម ភាពប្រឡាំប្រកូវ ជ្រុលនិយម សច្ចធម៌និងភក្ដីភាពនៃព្រហ្មចរិយ”។
7. ទស្សនៈផ្សេងៗ មានទស្សនៈផ្សេងៗច្រើនទៀត ដែលបានពន្យល់ពីព្រលឹងជាតិនេះ ដូចជា កតញ្ញូតាធម៌ ការខមាទោស ទស្សនៈកម្មផល ការធ្វើទាន ការខ្លាចបាប ការគោរពក្បួនច្បាប់ (ជំនឿ ទំនៀមទម្លាប់ ប្រពៃណី) ខ្មែរមិនចោលក្បួន មិនចោលស្រុក។ល។

*(នៅមានត)*

*ដោយលោក* **ស៊ឹម ហាក់** *សាស្រ្តាចារ្យអក្សរសាស្រ្តខ្មែរ*
*អតីតនាយកវិទ្យាល័យជាស៊ឹម សាមគ្គី*

## **ភាសិត**

សុជីវធម៌ជាពណ៌រស្មីមនុស្ស ជនស្រីប្រុសដែលខ្ពស់ថ្លៃថ្នូរបាន
ដោយមានឫកល្អប្រចាំប្រាណ ទើបថ្កើងថ្កានឆើតទាន់សម័យ។
សុជីវធម៌ជាជាតិឈាមជ័រខ្មែរ ដែលពូកែរាក់ទាក់មិនឆ្មើងឆ្មៃ
ជាតិចំណានចេះស៊ីវិល័យ តាំងពីសម័យអង្គរមក។

*សុង ស៊ីវ*




# ប្រវត្តបុណ្យចូលឆ្នាំខ្មែរ

សព្វថ្ងៃគេតែងនិយាយថា ពីដើមខ្មែរចូលឆ្នាំនៅខែមិគសិរ ប៉ុន្តែក្នុងខែមិគសិរនៅមានភ្លៀងធ្លាក់ ហើយប្រជាកសិករក៏នៅជាប់រវល់ការងារស្រែចំការផង ហេតុនេះហើយទើបគេនាំគ្នាចូលឆ្នាំនៅខែចេត្រវិញ ជាខែទំនេរពីការងារស្រែចំការ។

ខ្ញុំឆ្ងល់ថាបើចាត់ទុកខែចេត្រជាខែទំនេរពីការងារហេតុអ្វីក៏មិនចូលឆ្នាំនៅថ្ងៃ១កើត ខែចេត្រទៅគឺដាច់ខែផល្គុន ចូលឆ្នាំថ្មីនៅថ្ងៃទី១កើតទៅឲ្យដូចគេដូចឯង។ ឧទាហរណ៍ : ចិន-យួននៅស្រុកខ្មែរពេលដាច់ខែបុស្សចូល១កើត ខែមាឃ គឺគេចូលឆ្នាំថ្មីហើយ រីឯឆ្នាំសកលគឺដាច់ខែធ្នូចូលថ្ងៃទី១ ខែមករា គឺគេចូលឆ្នាំថ្មីហើយ។

ដូចនេះអ្នកពោលថា ចូលឆ្នាំខែចេត្រខែទំនេរ ដូចជាមិនត្រឹមត្រូវទេ ព្រោះឆ្នាំខ្លះខ្មែរចូលឆ្នាំដល់ខែពិសាខឯនោះ។

ខ្ញុំសូមទាញអារម្មណ៍អស់លោក លោកស្រី សង្កេតពីពិធីបុណ្យចូលឆ្នាំខ្មែរដូចតទៅ គឺខ្មែរចូលឆ្នាំក្នុងខែចេត្រមានពីរដងគឺ ម្ដងនៅក្នុងខ្នើតខែចេត្រ ម្ដងទៀតនៅក្នុងរនោចខែចេត្រ។ ដល់ឆ្នាំបន្ទាប់គឺចូលឆ្នាំនៅក្នុងខ្នើតខែពិសាខ គឺឆ្នាំដែលត្រូវលើកខែដែលមានខែអាសាធ២ដងគឺ បឋមាសាធ និងទុតិយាសាធ។ ដូចនេះមួយឆ្នាំមាន១៣ខែ។ លុះឆ្នាំបន្ទាប់នឹងត្រូវចូលឆ្នាំនៅក្នុងខែចេត្រវិញ និងបន្តបន្ទាប់ដូចបានរៀបរាប់ខាងលើ។

ខ្ញុំសូមបំភ្លឺពីប្រវត្តិបុណ្យចូលឆ្នាំខ្មែរដែលខ្ញុំបានចេះចាំ តាមរយៈព្រះសង្ឃ និងចាស់ៗព្រឹទ្ធាចារ្យក្នុងពេលដែលខ្ញុំរៀនសូត្រក្នុងវត្តអារាមតាំងពីខ្ញុំមានអាយុ១១ឆ្នាំម្ល៉េះ។

ជាបឋមខ្ញុំសូមជំរាបថា ខ្ញុំជាកូនកសិករ។ កាលពីក្មេងក្នុងអាយុ៧ ឬ៨ឆ្នាំ ខ្ញុំសង្កេតឃើញស្រមោលផ្ទះឪពុកម្ដាយខ្ញុំ ម្ដងចោលទៅខាងត្បូង ម្ដងចោលទៅខាងជើង។ ខ្ញុំឆ្ងល់ ខ្ញុំសួរម្ដាយខ្ញុំហេតុអ្វីបានដូចនេះ។ ម្ដាយខ្ញុំគាត់ប្រាប់ថា មកពីព្រះអាទិត្យលោកដើរម្ដងទៅខាងត្បូង ម្ដងទៅខាងជើងដើម្បីបំភ្លឺមនុស្សលោកឲ្យបានគ្រប់ៗគ្នា។ ដោយខ្ញុំនៅក្មេង ខ្ញុំពុំបានចាប់អារម្មណ៍រឿង

នេះទេ។ ទន្ទឹមនឹងនេះចាស់ៗនៅស្រុកខ្ញុំ តែងនិយាយថានៅថ្ងៃចូលឆ្នាំពេលថ្ងៃត្រង់ជាក់ អ្វីៗពុំមានឃើញស្រមោលទេ(ផ្ទះ ដើមឈើ មនុស្សឈរ) ដោយខ្ញុំនៅក្មេង ខ្ញុំពុំចាប់អារម្មណ៍នឹងពាក្យទាំងអស់នោះទេ។

លុះដល់ពេលខ្ញុំទៅរៀននៅឯវត្ត ខ្ញុំបានឮលោកគ្រូចៅអធិការ និងចាស់ព្រឹទ្ធាចារ្យ ២-៣នាក់ជជែកគ្នាពីរឿងបុណ្យចូលឆ្នាំខ្មែរ។

លោកគ្រូចៅអធិការលោកមានសង្ឃដីកាថា ពីដើមខ្មែរចូលឆ្នាំនៅក្នុងខែមិគសិរ។ ប៉ុន្តែដោយខែមិគសិរនៅមានភ្លៀងធ្លាក់ផង ហើយប្រជាកសិករនៅជាប់រវល់ការងារកសិកម្មផងទើបពួកហោរាសាស្ត្របានប្រជុំគ្នា ដើម្បីរិះរកថ្ងៃខែចូលឆ្នាំថ្មីឲ្យបានសមស្រប។ ក្រោយពីបានជជែកពិភាក្សាគ្នាអស់ជាច្រើនលើកច្រើនសាមក ពួកហោរាសាស្ត្រក៏បានឯកភាពគ្នាយកទៅតាមជំនឿរបស់ប្រជាជនខ្មែរដែលយល់ថាព្រះអាទិត្យធ្វើគោចរម្ដងទៅខាងត្បូង ម្ដងទៅខាងជើងនោះគឺដើម្បីបំភ្លឺមនុស្សជាតិឲ្យបានគ្រប់ៗគ្នា។ ដូចនេះថ្ងៃណាដែលព្រះអាទិត្យធ្វើគោចរមកចំពីលើក្បាលយើង នោះជាថ្ងៃសិរីសួស្ដីសំរាប់ពិធីបុណ្យចូលឆ្នាំថ្មីហើយ។

*(នៅមានត)*

*លោក* **ខោល តុន** (**និទត្តជន**)

នៃនាងក្រូចឆ្មា នៅក្នុងបន្លា កុំថារូចខ្លួន
ជូរឆ្មាស់ពីម៉ែ ហូរហែរដល់កូន ទោះខំកែខ្លួន
បានត្រឹមឃ្មុំង៉ូវ។

ចំណែកនាងស្វាយ ខ្ចីជូរពីម្ដាយ រហូតដល់ឪ
តែគេចេះកែ ប្រែតាមរដូវ ដល់ចាស់ទុំទៅ
ផ្អែមគួរគាប់ហោង។

ប៉ែកនាងននោង គ្រាខ្ចីដំបូង តែងមានអ្នកផង
រក្សាថ្នមថ្នាក់ មិនឲ្យមានឆ្កង ដល់ចាស់ស្វិតទង
បានត្រឹមដុសឆ្នាំង។

*លោកតា ធីង កាន*